# ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៣-៦-២០០៦ -ព្រះរាជក្រម នស/រកម/០៦០៦/០១៨ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ៥០១៩


### ២~ព្រះរាជក្រឹត្យ


១៣-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/៣០០ស្តីពីការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះសព ឯកឧត្តម **អាំ ណារិន្ទ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ៥០៣៨

១៤-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/៣០៣ ស្តីពីការតែងតាំងឧត្តមសេនីយ៍ត្រី **ម៉ឹក ដារ៉ា** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំង គ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន ៥០៣៩

១៤-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/៣០៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៥០៤០

១៨-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/៣០៦ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **អន ស៊ុំ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៥០៤២


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៤-៧-២០០៦ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ៥០៤៣

១៩-៧-២០០៦ -អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៥០៥០

១៩-៧-២០០៦ -អនុក្រឹត្យលេខ ៦៧ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងទេសចរណ៍ ៥០៥២

១៧-៧-២០០៦ -អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥០៥៤

១៧-៧-២០០៦ -អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៥០៧៤

**-អនុក្រឹត្យលេខ ៤៩០-៤៩១ អនក្រ.តត ពុំទាន់មានឯកសារ**

១៨-៧-២០០៦ -អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា អាណត្តិទី ៤ ៥០៧៥

១៨-៧-២០០៦ -អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥០៧៧

១៩-៧-២០០៦ -អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្តីពីការសំរួល ផ្លាស់ប្តូរ និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៥០៧៨

១៩-៧-២០០៦ -អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៨០

## ២.សេចក្តីសំរេច

១៧-៧-២០០៦ -សេចក្តីសំរេចលេខ ៣០ សសរ ស្តីពីការបង្កើតគណៈកម្មការចម្រុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធ ពេលអនុវត្តសេចក្តីសំរេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ៥០៨១

១៨-៧-២០០៦ -សេចក្តីសំរេចលេខ ៣១សសរ ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យខេត្តបាត់ដំបង ៥០៨៣

# III.ការងារបណ្តាក្រសួង

## ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៩-៦-២០០៦ -ប្រកាសលេខ ៧០៧ ឧរថ.កសឧ.ប្រក ស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម ៥០៨៥

## ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១០៧-២០០៦ -ប្រកាសលេខ ៣៨៤.ស.អ.យ ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិពហុផ្នែក ស្តីពីកុមារកំព្រា និង កុមារងាយរងគ្រោះ ៥១០៤

## ៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៥-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ិនសហ្វ ឌីវេឡុបមេន** ៥១០៨

២៥-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ទេលសេន(ខេមបូឌា) មីនើរ៉ល** ៥១១០

២៥-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៦៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អិមស៊ី អិម ភ្នំពេញ** ៥១១២

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៦៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហានូម អាសូស៊ីអេសិន ប្រាយវេត** ៥១១៤

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពិសិដ្ឋ អ៊ិនធើណេសិនណល គ្រេឌីង** ៥១១៦

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តី ឌី ធី (ខេមបូឌា) តីធីអ៊ី អិលធីឌី** ៥១១៨

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេធីវីស៊ី (ខេមបូឌា) ២០០៥ លីមីធីត** ៥១២០

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោល អ៊ីមផាយ ហ្វាម៉ាស៊ី & មេឌីខល អេឃ្វីបមេន អ៊ីមផត អិចផត ខមភេនី លីមីធីត** ៥១២២

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នីវឌ្ឍនៈ អ៊ីមផត អិចផត** ៥១២៤

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រាយដ៍ គ្លូបិល** ៥១២៦

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ុយជីហ៊្វន ខូ អិលធីឌី** ៥១២៨

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមអេនើជី អ៊ិនវេសមេន គ្រុប** ៥១៣០

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អេច.វើលដ៍ ត្រាវែល** ៥១៣២

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាហ្សាម៉ា ខបភើរេសិន** ៥១៣៤

២៦-៥-២០០៦ -លិខិតបញ្ជាក់លេខ ១៣៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លែន ហ្វារ តីធីវ៉ាយ អិលធីឌី** ៥១៣៦

| | | |
|---|---|---|
| ២៦-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៣៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បក្សា ខូ អិលធីឌី** | ៥១៣៨ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៣៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាក់ ចិន្តា ខនស្ត្រាក់សិន** | ៥១៤០ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៣៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ្រី ម៉ោនថិន** | ៥១៤២ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៣៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេ គីយ៉ុង ខនស្ត្រាក់សិន** | ៥១៤៤ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៤០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន**មីលេនៀម (ខេមបូឌា) អ៊ិនធើណេសិនណល គ្រុប** | ៥១៤៦ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៤០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូ ឆ័ន** | ៥១៤៨ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៤០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេហ្គា ប៊ី អេច គ្រុប** | ៥១៥០ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៤០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ហាយវេ** | ៥១៥២ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៤១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផាតនើរ អហ្វ ខនស្ត្រាក់សិន អេន ឌីវេឡុបមេន សឺវីស អ៊ីន** | ៥១៥៤ |
| ២៩-៥-២០០៦ | -លិខិតបញ្ជាក់លេខ ១៤១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិន.អ៊ី.ឌី** | ៥១៥៦ |

# ព្រះរាជក្រម

នស/រកម/០៦០៦/០១៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរោងចក្រ

# និងសិប្បកម្ម

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានវិសាលភាពចំពោះរោងចក្រ និងសិប្បកម្មទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយមិនប៉ះពាល់ដល់សមត្ថកិច្ចរបស់ក្រសួងស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធ ។

**មាត្រា ២.-**

រោងចក្រ និងសិប្បកម្មដែលមានចែងនៅក្នុងច្បាប់នេះ សំដៅទៅលើអគារ ទីកន្លែង ឬ យានយន្ត សម្រាប់ផលិត បំប្លែងវត្ថុធាតុដើម ឬ ផលិតផលពាក់កណ្តាលសម្រេចឱ្យទៅជាផលិតផលថ្មី ឬ/និង សម្រាប់ធ្វើសកម្មភាពផ្សេងទៀត ដែលមានជាអាទិ៍ ផ្គុំ ដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលម្អ ដើម្បីបម្រើសេចក្តីត្រូវការទីផ្សារ ។

**មាត្រា ៣.-**

រោងចក្រ និងសិប្បកម្មដែលស្ថិតក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានដូចខាងក្រោម:

១-ផ្នែកស្បៀង ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់

២-ផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់ និងផលិតផលអំពីស្បែក

៣-ផ្នែកផលិតផលក្រដាស

៤-ផ្នែក គីមី ផលិតផលពីកៅស៊ូ ផ្លាស្ទិច លើកលែងតែឧស្សាហកម្មប្រេងកាត និងឧស្ម័ន

៥-ផ្នែកផលិតផលពីរ៉ែអលោហៈ

៦-ផ្នែកលោហៈមូលដ្ឋាន

៧-ផ្នែកកែច្នៃលោហៈ ម៉ាស៊ីន និង គ្រឿងបរិក្ខារ

ꔊ

៨-ផ្នែកផ្សេងទៀតមានជាអាទិ៍ ផលិតគ្រឿងអលង្ការ រតនភ័ណ្ឌ និងលម្អ ឧបករណ៍សិល្បៈ កីឡា ក្មេងលេង និងសម្ភារៈការិយាល័យ ។

## ជំពូកទី ២
## ការបង្កើត និងកិច្ចដំណើរការ
## ផ្នែកទី ១
## រោងចក្រ

**មាត្រា ៤.-**

ការបង្កើតរោងចក្រដែលមានចែងក្នុងមាត្រា ៣ ត្រូវមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយមានយោបល់ឯកភាពពីក្រសួងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ។ ការបង្កើតរោងចក្រផ្តោតសំខាន់ទៅលើ :

-ការរៀបចំ ទីកន្លែង ឬ/និង ការសាងសង់អគារ សម្រាប់ដំណើរការរោងចក្រ

-ការសាងសង់អគារ សម្រាប់បំពាក់ម៉ាស៊ីន ដើម្បីដំណើរការរោងចក្រ

-ការបំពាក់ម៉ាស៊ីន ក្នុងអគារ ទីកន្លែង ឬយានយន្ត សម្រាប់ដំណើរការរោងចក្រ

-វត្ថុធាតុដើមសម្រាប់ដំណើរការរោងចក្រ ។

**មាត្រា ៥.-**

ម្ចាស់រោងចក្រត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ។ ម្ចាស់រោងចក្រអាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់និងអ្នកប្រើប្រាស់ ។

5/20

**មាត្រា ៦.-**

ការត្រួតពិនិត្យគុណភាព ការកំណត់ស្តង់ដា ការចុះបញ្ជី និងសញ្ញាបញ្ជាក់ផលិត-ផលត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ៧.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្តល់លិខិតបញ្ជាក់ផ្សេងៗពាក់ព័ន្ធនិងផលិត-កម្មតាមការស្នើសុំរបស់ម្ចាស់រោងចក្រ បើពិនិត្យឃើញថាជាការចាំបាច់ ។

**មាត្រា ៨.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកសុំបង្កើតរោងចក្រ ក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ យ៉ាងយូរនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ក្នុងករណីមិនយល់ព្រមលើពាក្យសុំបង្កើតរោងចក្រ ក្រសួងឧស្សាហកម្ម រ៉ែ និងថាម-ពល ត្រូវពន្យល់ហេតុផលលើការសម្រេចរបស់ខ្លួនឱ្យបានច្បាស់លាស់ ។

**មាត្រា ៩.-**

មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងទៅក្រសួងឧស្សាហ-កម្ម រ៉ែ និង ថាមពលឱ្យបានមុនរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ យ៉ាងតិច ។

**មាត្រា ១០.-**

ក្នុងការបង្កើតនិងកិច្ចដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវប្រើប្រាស់វិស្វករ ឬ អ្នកបច្ចេកទេស ដែលមានសញ្ជាតិខ្មែរជាអាទិភាព ។ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់វិស្វករ អ្នកបច្ចេកទេសបរទេស ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ១១.-**

ក្នុងការពង្រីក ឬ ការបង្កើតសាខា ឬ ការផ្លាស់ប្តូរទីតាំងរោងចក្រត្រូវតែមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១២.-**

ការពង្រីករោងចក្រ គឺជាការបង្កើនសមត្ថភាពផលិតកម្មលើសពី ២០ (ម្ភៃ) ភាគរយ នៃសមត្ថភាពដើម ដោយ ៖

១-ការបង្កើនចំនួនម៉ាស៊ីន ឬ ការផ្លាស់ប្តូរម៉ាស៊ីន

២-ការរុះរើដើម្បីរៀបចំ ឬ ការពង្រីក ឬ ការសាងសង់អគារ

៣-ការផ្លាស់ប្តូរមុខផលិតផល ឬ បន្ថែមមុខផលិតផល

៤-ការពង្រីកបរិវេណរោងចក្រ ។

ការបង្កើតសាខារោងចក្រ គឺជាការបង្កើតមូលដ្ឋានផលិតកម្មថ្មី ដែលធ្វើផលិតកម្មបម្រើឱ្យរោងចក្រដើម ។

ការផ្លាស់ប្តូរទីតាំង គឺការផ្លាស់ប្តូររោងចក្រពីទីតាំងចាស់ទៅទីតាំងថ្មី ។

**មាត្រា ១៣.-**

ក្នុងករណីប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មី ត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រថ្មី ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវឆ្លើយតបទៅម្ចាស់រោងចក្រវិញក្នុងរយៈពេល ០៤ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**មាត្រា ១៤.-**

ក្នុងករណីដែលម្ចាស់រោងចក្រទទួលមរណភាព ឬ អសមត្ថភាពតាមផ្លូវច្បាប់ អ្នកដែលទទួលសិទ្ធិគ្រប់គ្រងបន្តស្របច្បាប់ ត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬ បាត់បង់សមត្ថភាពតាមផ្លូវច្បាប់ ។

អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត អាចដំណើរការរោងចក្រជាបណ្តោះអាសន្នបានរហូតមានការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១៥.-**

ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល រយៈពេល ១(មួយ)ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។

ក្រៅពីករណីប្រធានសក្តិ ការផ្អាកដំណើរការរោងចក្រជាប់ៗគ្នាក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។ ក្នុងករណីនេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញប្រកាសលុបប្រកាសអនុញ្ញាតបង្កើតរោងចក្រ ។

**មាត្រា ១៦.-**

ម្ចាស់រោងចក្រត្រូវតាំងបង្ហាញ ប្រកាសបង្កើតរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយជាចំហនៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ។

**មាត្រា ១៧.-**

ក្នុងករណីដែលប្រកាសបង្កើតរោងចក្រ ឬ/និង លិខិតអនុញ្ញាតទាំងឡាយ ត្រូវបានបាត់បង់ដោយប្រការណាមួយ ម្ចាស់រោងចក្រត្រូវធ្វើពាក្យសុំប្រកាស ឬ លិខិតជំនួសមួយទៀតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលបានបាត់បង់ ។

**មាត្រា ១៨.-**

រោងចក្រនីមួយៗ ត្រូវមានឈ្មោះរោងចក្រ ហើយផ្លាកឈ្មោះត្រូវសរសេរជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត ។ ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន នៅកន្លែងដែលងាយមើលឃើញ នៅខាងមុខរោងចក្រ ។

ការផ្លាស់ប្តូរឈ្មោះរោងចក្រ ត្រូវតែមានការយល់ព្រមពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

4

**មាត្រា ១៩.-**

ម្ចាស់រោងចក្រត្រូវផ្តល់ឱ្យ បានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ចាំបាច់នានាតាមការកំណត់របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២០.-**

ម្ចាស់រោងចក្រដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៩ ។

**មាត្រា ២១.-**

ទិន្នន័យ និងរបាយការណ៍ ដែលរោងចក្រផ្តល់ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គឺជាការសម្ងាត់វិជ្ជាជីវៈរបស់រោងចក្រ ។ ទិន្នន័យ និងរបាយការណ៍ទាំងនេះមិនត្រូវបានយកទៅផ្សព្វផ្សាយជាសាធារណៈឡើយ បើគ្មានការយល់ព្រមពីម្ចាស់រោងចក្រ ។

**មាត្រា ២២.-**

ម្ចាស់រោងចក្រ ដែលស្ថិតនៅក្រោមច្បាប់នេះ មានកាតព្វកិច្ចបង់ប្រាក់កម្រៃសេវាកម្មស្របតាមការកំណត់នៃប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## សិប្បកម្ម

**មាត្រា ២៣.-**

សិប្បកម្មត្រូវបានអនុញ្ញាតឱ្យបង្កើតនិងដំណើរការ ដោយម្ចាស់សិប្បកម្មត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលខ្លួនបោះទីតាំងក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ) ថ្ងៃ ក្រោយថ្ងៃដំណើរការ លើកលែងតែប្រភេទសិប្បកម្មដែលមានកំណត់ដោយប្រកាស

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុនដំណើរការ ។

បែបបទនៃការបង្កើតនិងកិច្ចដំណើរការ សិប្បកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ៣
## សុវត្ថិភាពឧស្សាហកម្ម

**មាត្រា ២៤.–**

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេសដែលត្រូវបាន កំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្រ បានឡើយ ។

**មាត្រា ២៥.–**

គ្រប់ផ្នែកនៅក្នុងរោងចក្រត្រូវធានានិងរក្សាឱ្យមានពន្លឺគ្រប់គ្រាន់ និងខ្យល់ចេញចូល បរិបូរណ៍ ត្រូវធានានូវភាពគ្មានគ្រោះថ្នាក់ដែលជាអាទិ៍បណ្តាលមកពី វិទ្យុសកម្ម សំឡេង ញ័រ ពន្លឺ កាំរស្មី ក្លិន ចំហាយ កំដៅ ផ្សែង ធូលី និង ភាពកខ្វក់ផ្សេងៗទៀត ។

**មាត្រា ២៦.–**

រោងចក្រត្រូវតែមានប្រព័ន្ធបង្ការអគ្គីភ័យ ដែលរួមមាន :

១-ប្រព័ន្ធប្រកាសភាពអាសន្ន និង មធ្យោបាយសម្រាប់ពន្លត់អគ្គីភ័យ

២-សញ្ញាប្រយ័ត្នអគ្គីភ័យ នៅកន្លែងដែលចាំបាច់

៣-ទ្វារសង្គ្រោះយ៉ាងតិចបំផុតមានចំនួនពីរ នៅតាមជាន់នីមួយៗ

៤-ផ្លូវសង្គ្រោះ សម្រាប់រថយន្តពន្លត់អគ្គីភ័យ

៥-មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត

៦-ប្លង់បំព្រួញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន ។

**មាត្រា ២៧.-**

ម៉ាស៊ីន ឬ ផ្នែកនៃម៉ាស៊ីន ដែលអាចបង្កឱ្យមានគ្រោះថ្នាក់បានជាយថាហេតុ ត្រូវមានគម្រប ឬ ឧបករណ៍ការពារ ។ ផ្នែកនៃរោងចក្រ ដែលមានគ្រោះថ្នាក់ខ្ពាំងត្រូវធ្វើរបាំងព័ទ្ធជុំវិញ ។

**មាត្រា ២៨.-**

ត្រូវមានសញ្ញាបង្ហាញប្រាប់ប្រយ័ត្នគ្រោះថ្នាក់ ឬ បំរាមនៅកន្លែងដែលមានគ្រោះថ្នាក់ ។

**មាត្រា ២៩.-**

ការប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុល គីមីគ្រោះថ្នាក់ ឬ ឧស្ម័ន ក្នុងផលិតកម្ម ត្រូវប្រតិបត្តិទៅតាមលក្ខណៈបច្ចេកទេស ដែលធានាបាននូវសុវត្ថិភាព ។

**មាត្រា ៣០.-**

ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយ ឧបករណ៍ ឬ ធុងដែលប្រើសម្ពាធខ្ពស់ ត្រូវមានការត្រួតពិនិត្យពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមុននឹងអនុញ្ញាតឱ្យដំណើរការ ។ នៅពេលដំណើរការ ការត្រួតពិនិត្យឧបករណ៍ខាងលើនេះ ត្រូវធ្វើឡើងតាមដំណាក់កាលដែលកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៣១.-**

សំណល់ឧស្សាហកម្មគ្រប់ប្រភេទ មុននឹងបញ្ចេញចោល ត្រូវឆ្លើយតបទៅនឹងកម្រិតបទដ្ឋាននៃការបញ្ចេញសំណល់ ឬ សារធាតុបំពុល ដែលកំណត់ដោយបទប្បញ្ញត្តិរបស់ស្ថាប័នមានសមត្ថកិច្ច ។

ហាមដាច់ខាតចំពោះការបញ្ចេញចោលសំណល់ឧស្សាហកម្ម ដែលមានជាតិពុល ឬ សារធាតុបំពុលដែលនាំឱ្យកខ្វក់ ឬ ប៉ះពាល់ដល់បរិស្ថាន ដោយមិនបានឆ្លងកាត់ប្រព្រឹត្តិកម្មជាមុន ។

ចំពោះសំណល់ឧស្សាហកម្ម ដែលត្រូវយកមកប្រើប្រាស់ឡើងវិញ ត្រូវរក្សាទុកឱ្យបានគត់មត់តាមយថាប្រភេទ និងលក្ខណៈបច្ចេកទេស ។

**មាត្រា ៣២.-**

សំណល់ឧស្សាហកម្មគ្រប់ប្រភេទ ដែលមិនអាចធ្វើប្រព្រឹត្តិកម្មបាន ឬ ដែលបានឆ្លងកាត់ប្រព្រឹត្តិកម្មរួចហើយ តែនៅមានជាតិពុល ឬ មានសារធាតុបំពុលដែលនាំឱ្យកខ្វក់ ឬ ប៉ះពាល់ដល់បរិស្ថាន ឬ មានសារធាតុវិទ្យុសកម្ម មុននឹងបញ្ចេញចោល ឬ ដឹកជញ្ជូនយកទៅកន្លែងដទៃទៀតដើម្បីរក្សាទុក ឬ ដើម្បីគោលបំណងណាមួយផ្សេង ត្រូវមានការត្រួតពិនិត្យ និងមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៣៣.-**

ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការបញ្ចេញចោល ការសម្អាត និងការទុកដាក់សំណល់ឧស្សាហកម្ម គ្រប់ប្រភេទរបស់រោងចក្រ ។

**មាត្រា ៣៤.-**

ក្នុងការអនុវត្តច្បាប់នេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសមត្ថកិច្ចចេញលិខិតបទដ្ឋាន ឬ ស្នើទៅរាជរដ្ឋាភិបាលបង្កើតជាអនុក្រឹត្យ ដើម្បីគ្រប់គ្រងរោងចក្រ ។

## ជំពូកទី ៤
## ការទ្រទ្រង់ និងការលើកទឹកចិត្ត

**មាត្រា ៣៥.-**

ការទ្រទ្រង់ និងការលើកទឹកចិត្តដើម្បីអភិវឌ្ឍរោងចក្រធុនធំ ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៦.-**

ចំពោះរោងចក្រធុនមធ្យម តូច និងសិប្បកម្មត្រូវបានអនុញ្ញាតឱ្យមានការទ្រទ្រង់ និងការលើកទឹកចិត្តដោយរាជរដ្ឋាភិបាល ។ ប្រភេទ ទំហំ និងរូបភាពនៃការទ្រទ្រង់ និងការលើកទឹកចិត្ត ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## ការត្រួតពិនិត្យ និងអធិការកិច្ចរោងចក្រ

**មាត្រា ៣៧.-**

មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចូលទៅក្នុងរោងចក្រ និងសិប្បកម្ម គ្រប់ម៉ោងធ្វើការរបស់រោងចក្រតាមកាលកំណត់ ឬ មិនតាមកាលកំណត់ ដើម្បីត្រួតពិនិត្យគុណភាព ស្ថានភាព រោងចក្រ ម៉ាស៊ីន មធ្យោបាយនានា ឬ សកម្មភាពផ្សេងៗទៀត ដែលម្ចាស់រោងចក្ររំលោភទៅលើបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើអធិការកិច្ចរោងចក្រដោយ :

១-យកផលិតផលក្នុងបរិមាណសមស្រប ដើម្បីធ្វើការវិភាគអំពីគុណភាពរួមជាមួយនឹងឯកសារពាក់ព័ន្ធ ។

២-ធ្វើការស្រាវជ្រាវ បញ្ឈប់ ឬ ឃាត់ទុកនូវផលិតផល សម្ភារៈ វត្ថុធាតុដើម និងឯកសារពាក់ព័ន្ធនានា ដែលអាចបណ្តាលឱ្យមានអន្តរាយដល់មនុស្ស ឬ ដល់ទ្រព្យសម្បត្តិក្នុងរោងចក្រ ឬ ទីជិតខាងរោងចក្របាន ។

៣-សាកសួរ ឬ កោះអញ្ជើញម្ចាស់រោងចក្រ អ្នកគ្រប់គ្រងរោងចក្រ និយោជិត ឬ កម្មករក្នុងរោងចក្រ មកបំភ្លឺព័ត៌មាន ឬ សុំឱ្យផ្តល់ព័ត៌មាននិងឯកសារ ។

**មាត្រា ៣៨.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានសិទ្ធិផ្អាកសកម្មភាពរោងចក្រទាំងឡាយណាដែលបានបង្កើតដោយគ្មានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីតម្រូវឱ្យម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវកំហុសរបស់ខ្លួនឡើងវិញ ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវ និងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញប្រកាសអនុញ្ញាតឱ្យបង្កើតរោងចក្រ ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬ អនុវត្តមិនត្រឹមត្រូវ ឬ មិនទាន់តាមកាលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ហាផ្អាកដំណើរការផលិតកម្ម ឬ ប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈនៅពីមុខរោងចក្រ ឬ ចុះផ្សាយតាមសារព័ត៌មាន ។

**មាត្រា ៣៩.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចេញបញ្ជាឱ្យម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រផ្អាកដំណើរការផលិតកម្មទាំងមូល ឬ តាមផ្នែកនៃរោងចក្រជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីឱ្យម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវ ឬ កែលម្អឱ្យបានប្រសើរឡើងវិញ ក្នុងករណី :

- មានកំហុសធ្ងន់ធ្ងរផ្នែកបច្ចេកទេស ដូចមានចែងក្នុងមាត្រា ២៤
- កិច្ចដំណើរការផលិតកម្មខុសពីការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- កិច្ចដំណើរការផលិតកម្ម ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬ អន្តរាយដល់ទ្រព្យសម្បត្តិ នៅក្នុងរោងចក្រ ឬ ក្រៅរោងចក្រ
- ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ មានចេតនាមិនគោរពតាមលិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវនិងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញបញ្ជាអនុញ្ញាតឱ្យរោងចក្របន្តដំណើរការផលិតកម្មឡើងវិញ ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬ អនុវត្តមិនទាន់កាលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានអំណាចចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ហាផ្អាកដំណើរការផលិតកម្ម ឬ ប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈ នៅពីមុខរោងចក្រ ឬ ចុះផ្សាយតាមសារព័ត៌មាន ។

14/20

**មាត្រា ៤០.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិបញ្ជូនលិខិតបញ្ជាទៅកាន់គេហដ្ឋាន ឬរោងចក្ររបស់ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ដែលត្រូវទទួលលិខិតបញ្ជានេះ ដោយផ្ទាល់ ឬ តាមសំបុត្រអនុសិដ្ឋ ដោយមានចុះហត្ថលេខាបានទទួល ។

ក្នុងករណីដែលម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រនោះ បដិសេធមិនព្រមទទួល លិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិអញ្ជើញអាជ្ញាធរ ឬ ភ្នាក់ងារនគរបាលឱ្យចូលរួមជាមួយខ្លួនដើម្បីធ្វើជាសាក្សី ។ បើម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រមិនស្ថិតក្នុងគេហដ្ឋាន ឬ ក្នុងរោងចក្រទេនោះ លិខិតបញ្ជាអាចត្រូវបានប្រគល់ទៅឱ្យជនណាម្នាក់ ដែលមានការពាក់ព័ន្ធតាមផ្លូវច្បាប់ជាមួយនឹងម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ។

ប្រសិនបើលិខិតបញ្ជានៅតែគ្មានអ្នកទទួលជំនួស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបិទលិខិតបញ្ជានោះនៅច្រកចូល ឬ មាត់ទ្វាររោងចក្រ ឬ នៅគេហដ្ឋានរបស់ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រនោះ ដោយមានវត្តមានរបស់អាជ្ញាធរ ឬ ភ្នាក់ងារនគរបាលជាសាក្សី ។

ក្រោយពីបានប្រតិបត្តិដូចបានចែងក្នុងវាក្យខ័ណ្ឌខាងលើ លិខិតបញ្ជាត្រូវបានចាត់ទុកថាបានទទួលដោយម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ។

**មាត្រា ៤១.-**

ក្នុងករណីដែលមានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្តាលឱ្យរោងចក្រត្រូវផ្អាកដំណើរការទាំងស្រុងលើសពី ៧ (ប្រាំពីរ)ថ្ងៃ ម្ចាស់រោងចក្រ ឬ អ្នកគ្រប់គ្រងរោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុនោះ ។

ពេលដែលមានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់កើតឡើងដូចខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើអធិការកិច្ចរោងចក្រហើយអនុវត្តតាមមាត្រា ៣៧ ឬ មាត្រា ៣៩ វាក្យខ័ណ្ឌទី ១ ប្រសិនបើចាំបាច់ ។

**មាត្រា ៤២.-**

ក្នុងការចុះធ្វើអធិការកិច្ច មន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវបង្ហាញប័ណ្ណសម្គាល់ខ្លួន និងលិខិតបញ្ជាបេសកកម្ម ជូនទៅម្ចាស់រោងចក្រ ឬ ជនដែលខ្លួនត្រូវទំនាក់ទំនង ។

ការធ្វើអធិការកិច្ចរោងចក្រ ត្រូវមានកំណត់ហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ៤៣.-**

ម្ចាស់សិប្បកម្មណា ដែលពុំបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលខ្លួនបានបោះទីតាំងដូចកំណត់ក្នុងមាត្រា ២៣ វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០រៀល (ប្រាំរយពាន់រៀល) ទៅ ២.៥០០.០០០រៀល (ពីរលានប្រាំរយពាន់រៀល) ។

ជនណាបង្កើតប្រភេទសិប្បកម្ម ដែលមានចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចក្នុងមាត្រា ២៣ ដោយគ្មានការអនុញ្ញាត ឬ ល្មើសនឹងមាត្រា ២៣ ឬ បទប្បញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងមាត្រា ២៣ វាក្យខ័ណ្ឌទី ២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ទៅ ៥.០០០.០០០រៀល(ប្រាំលានរៀល) ។

**មាត្រា ៤៤.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១១ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ វាក្យខ័ណ្ឌទី ១ មាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ មាត្រា ៤១ វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០រៀល (ពីរលានរៀល) ទៅ ១០.០០០.០០០ រៀល (ដប់លានរៀល) ។

**មាត្រា ៤៥.-**

ម្ចាស់រោងចក្រណា ដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០រៀល (ប្រាំលានរៀល) ទៅ ២៥.០០០.០០០រៀល (ម្ភៃប្រាំលានរៀល) ។

ប្រសិនបើមានគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រព្រឹត្តល្មើសនឹងមាត្រាខាងលើ ម្ចាស់រោងចក្រត្រូវទទួលសំណងខូចខាតទាំងអស់ដល់ជនរងគ្រោះ ។ ក្នុងករណីនេះ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។

**មាត្រា ៤៦.-**

ម្ចាស់រោងចក្រណា ដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ រៀល (ពីរលានរៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) ។

ក្នុងករណីបទល្មើសនេះបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬ អន្តរាយដល់ទ្រព្យសម្បត្តិក្នុង ឬ ក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមល្មសនកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៤៧.-**

ជនណាដែលមិនផ្តល់ ឬ ផ្តល់របាយការណ៍មិនពិត ឬ ប្រព្រឹត្តល្មើសនឹងមាត្រា ១៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១០.០០០.០០០រៀល (ដប់លានរៀល) ទៅ ៥០.០០០.០០០រៀល (ហាសិបលានរៀល) និងផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា ៤៨.-**

ជនណាដែលដំណើរការរោងចក្រ ដោយប្រព្រឹត្តល្មើសនឹងមាត្រា ៣៨ វាក្យខ័ណ្ឌទី ១ និងមាត្រា ៣៩ វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០

រៀល (ម្ភៃលានរៀល) ទៅ ១០០.០០០.០០០រៀល (មួយរយលានរៀល)ឬ/និងទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ១ ឆ្នាំ ។

ក្នុងករណីដែលការប្រព្រឹត្តល្មើសនឹងមាត្រា ៣៩ វាក្យខ័ណ្ឌទី ៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣០.០០០.០០០រៀល (សាមសិបលានរៀល) ដល់ ១៥០.០០០.០០០ រៀល (មួយរយហាសិបលានរៀល) ឬ/និងទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ ។

**មាត្រា ៤៩.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤ មាត្រា ៩ និងមាត្រា ២០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០រៀល (ដប់លានរៀល) ទៅ ៥០.០០០.០០០រៀល (ហាសិបលានរៀល) ។

ក្នុងករណីបទល្មើសនេះបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬ អន្តរាយទ្រព្យសម្បត្តិក្នុង ឬ ក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមលុសនកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៥០.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០ និងមាត្រា ២៥ នៃច្បាប់នេះ ត្រូវទទួលទោស និងសំណងតាមច្បាប់ស្តីពីការងារ ។

**មាត្រា ៥១.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣១ មាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលទោស និងសំណងតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៥២.-**

មន្ត្រីមានសមត្ថកិច្ចណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៨ វាក្យខ័ណ្ឌទី ១ និងមាត្រា ២១ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល តាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជ-ការស៊ីវិល ឬ ផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០រៀល (ពីរលានរៀល) ទៅ

១០.០០០.០០០ រៀល (ដប់លានរៀល) និងផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ ខែ ទៅ ១ ឆ្នាំ ឬ ទោសណាមួយ ។

**មាត្រា ៥៣.-**

ជនណាដែលរារាំង ប្រឆាំងនឹងការអនុវត្តច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ២.០០០.០០០រៀល (ពីរលានរៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួនពី ១ ខែ ទៅ ៦ ខែ ។

**មាត្រា ៥៤.-**

ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសហើយពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរតាមបទល្មើសនៃមាត្រានីមួយៗក្នុងជំពូកនេះ ។

**មាត្រា ៥៥.-**

ទោសទណ្ឌទាំងឡាយណាដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០រៀល(ប្រាំរយពាន់រៀល) ទៅ ១០.០០០.០០០រៀល (ដប់លានរៀល) មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិពិន័យអន្តរការណ៍ ។

ក្នុងករណីរឹងរូស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៦.-**

ក្រោយពីច្បាប់នេះចូលជាធរមាន រោងចក្រ សិប្បកម្មទាំងអស់ ដែលបានបង្កើតរួចហើយ និងមិនទាន់មានប្រកាសបង្កើតរោងចក្រ ឬ លិខិតអនុញ្ញាត ឬ មិនទាន់បានចុះបញ្ជី ត្រូវមកបំពេញសំណុំបែបបទឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬ នៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលសិប្បកម្មនោះ

ទីតាំងក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ យ៉ាងយូរ ។ ក្នុងករណីចាំបាច់ រយៈពេលនេះអាចបន្តបាន ៣(បី)ខែ បន្ថែម ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.០២៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ហត្ថលេខា**

**ស៊ុយ សែម**

លេខ : ៤៦៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស/រកត/០៧០៦/៣០០

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះសព

ឯកឧត្តម **អាំ ណារិទ្ធ**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ២៤៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

៣រល-០៦០៧.៣២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦

នស/រកត/០៧០៦/៣០៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឧត្តមសេនីយ៍ត្រី ម៉ឹក ដារ៉ា ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៦០៧.៣៧៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦*

លេខ : ២៩០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៦/៣០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៣ថ្មី នៃច្បាប់ស្តីពីច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០២ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៣
- បានទ្រង់យល់លិខិតលេខ ៧៧១ រស ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៥ របស់រដ្ឋសភា ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាសភាពគណៈគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានសមាសភាពដូចតទៅនេះ :

១-ឯកឧត្តម **អ៊ឹម សូស្តី** ប្រធាន

២-លោកជំទាវ ស៊ុន ជុំចូ អនុប្រធាន
៣-លោកជំទាវ កុយ ទ័ត សមាជិកា
៤-ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក
៥-ឯកឧត្តម ហាវ៉ាណា ស៊ីវិលំយ សមាជិក
៦-ឯកឧត្តម មាន សតិ សមាជិក
៧-ឯកឧត្តម ឯម សុផាត សមាជិក
៨-ឯកឧត្តម សោម ចំនួឌីណា សមាជិក
៩-ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និង ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដាឆ្នាំ២០០៦*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៖ស.០៦០៧.៣២៦

បានក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ : ២ ៧៩៦.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦
**អគ្គលេខាធិការនៃរាជរដ្ឋាភិបាល**
**ឃុន ជីនកេន**

នស/រកត/០៧០៦/៣០៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

ចំពោះ

ឯកឧត្តម **អន ស៊ុំ**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០៧០៦.៣៦៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ២៩៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ០២០៦/ ០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមសំណើប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់អំពីបេសកកម្ម សិទ្ធិអំណាច មុខងារ ភារកិច្ច និង រចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានតួនាទីជាអង្គភាពប្រតិបត្តិ និង ជាសេនាធិការផ្ទាល់នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលត្រូវដឹកនាំ និង គ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និង អមដោយអគ្គលេខាធិការរង ព្រមទាំងសមាជិកមួយចំនួនជាជំនួយការ ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានបេសកកម្មជួយអាជ្ញាធរក្នុងការដោះស្រាយ និង សម្របសម្រួលចំពោះវិវាទដីធ្លី និង មានភារកិច្ចដូចកំណត់ក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។ ទន្ទឹមនឹងនេះ យោងតាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិចេញលិខិតណែនាំឱ្យផ្អាកជាបណ្តោះអាសន្នទីតាំងទំនាស់ មិនឱ្យធ្វើសកម្មភាពផ្សេងៗ ក្រោយពីទទួលពាក្យបណ្តឹង ឬពាក្យសុំអន្តរាគមន៍ពីគូវិវាទ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយខែម្តង តាមការអញ្ជើញ និង ការណែនាំរបស់អគ្គលេខាធិការ ហើយក្នុងករណីចាំបាច់អាចធ្វើការកោះប្រជុំភ្លាម ។

**មាត្រា ៥.-**

អគ្គលេខាធិការ ត្រូវលើកសំណើជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីពិនិត្យ និង សម្រេចតែងតាំង តម្លើងឋានៈ ផ្ទេរភារកិច្ច ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**មាត្រា ៦.-**

អគ្គលេខាធិការ មានជំនួយការពីររូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពេលបំពេញភារកិច្ច និង បេសកកម្មរបស់ខ្លួន ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ :

១- នាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំ

២- នាយកដ្ឋានស៊ើបអង្កេត និង អធិការកិច្ច

៣- នាយកដ្ឋានទទួល និង ដោះស្រាយបណ្តឹង

៤- នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និង ទំនាក់ទំនងសាធារណៈ

៥- នាយកដ្ឋានរដ្ឋបាល និង បុគ្គលិក

**មាត្រា ៩.-**

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំ និង គ្រប់គ្រងដោយប្រធានមួយរូប និង មានអនុប្រធានមួយចំនួនជាជំនួយការ ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាចស្នើសុំបង្កើតនាយកដ្ឋានផ្សេងទៀតតាមតម្រូវការចាំបាច់ ។

**មាត្រា ១០.-**

**នាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំ មានតួនាទី និង ភារកិច្ចដូចតទៅ:**

១- លើកផែនការបណ្តុះបណ្តាល និង ផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និង ប្រជាពលរដ្ឋទូទៅឱ្យយល់ដឹងអំពីបញ្ហា និង ផលវិបាកដែលកើតមានឡើងពីវិវាទដីធ្លី ។

២- រៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ភូមិភាគ ជាតិ និង អន្តរជាតិ និង បង្កើតកម្មវិធីផ្សេងៗ ដើម្បីផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល និង គោលការណ៍របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ស្តីពីការអប់រំ ការបង្ការ ការទប់ស្កាត់ទំនាស់ដីធ្លី សំដៅឱ្យសាធារណជនយល់ដឹងពីផលវិបាកនៃទំនាស់ដីធ្លី និង ឈានទៅកាត់បន្ថយបានជាអតិបរមានូវបញ្ហាទំនាស់ដីធ្លី ។

៣- ជំរុញ និង លើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ រួមមានសង្គមស៊ីវិល និង អង្គការក្រៅរដ្ឋាភិបាលនានា ឱ្យចូលរួមផ្តល់ព័ត៌មាន និង អនុសាសន៍នានា សំដៅបង្ការ ទប់ស្កាត់នូវរាល់បញ្ហាទំនាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ។

៤- សហការជាមួយស្ថាប័នជាតិ និង អន្តរជាតិ ដើម្បីស្វែងរកការឧបត្ថម្ភពីដៃគូនានា ក្នុងគោលដៅបង្កើនល្បឿននៃការដោះស្រាយទំនាស់ដីធ្លី ជាពិសេសការអប់រំ បង្ការ ទប់ស្កាត់នូវរាល់បញ្ហាទំនាស់ដីធ្លីតាមគ្រប់រូបភាព ។

៥- ស្នើសុំ និង ទទួលយកគោលការណ៍ពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក្នុងការចាត់វិធានការ និង អនុវត្តភារកិច្ចនីមួយៗ ដើម្បីបង្ការ ទប់ស្កាត់ និង អប់រំ អំពីបញ្ហាទំនាស់ដីធ្លីគ្រប់រូបភាព ។

៦- រៀបចំផលិតឯកសារអប់រំ និង ល្ខោនវីដេអូផ្សេងៗ ក្នុងគោលដៅអប់រំសាធារណជន តាមរយៈការចុះអប់រំផ្ទាល់ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំពីផលវិបាក នៃបញ្ហាដែលកើតមានឡើងពីវិវាទដីធ្លី ។

៧- សម្របសម្រួល និង សហការជាមួយស្ថាប័នជំនាញដទៃទៀតដើម្បីប្រមូល និង ផ្លាស់ប្តូរព័ត៌មានគ្នា សំដៅបង្ការ និង ទប់ស្កាត់ឱ្យបាននូវបញ្ហាទំនាស់ដីធ្លី និង សំដៅជំរុញការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព និង តម្លាភាពខ្ពស់ ។

៨- រៀបចំជាកម្មវិធីទស្សនកិច្ចសិក្សា ដើម្បីដកស្រង់បទពិសោធនទាំងក្នុង និង ក្រៅប្រទេស ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និង ការជំរុញអនុវត្តការងារដោះស្រាយទំនាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ។

**មាត្រា ១១.-**

**នាយកដ្ឋានស៊ើបអង្កេត និង អធិការកិច្ច មានតួនាទី និងភារកិច្ចដូចតទៅៈ**

**ក- អំពីការងារស៊ើបអង្កេត**

១-តាក់តែង និង រៀបចំនីតិវិធី និង បែបបទរាយការណ៍ស្តីពីការផ្តល់ព័ត៌មានទូវរាល់ទំនាស់ដីធ្លី និង បង្កើតឡើងនូវយន្តការស៊ើបអង្កេតមួយប្រកបដោយលក្ខណៈរលូន មានតម្លាភាព និង ប្រសិទ្ធភាព។

២-ទទួលអនុវត្តបទបញ្ជាទាំងឡាយរបស់អគ្គលេខាធិការ នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ពាក់ព័ន្ធទៅនឹងដំណើរការស្រាវជ្រាវ និង ស៊ើបអង្កេតករណីទំនាស់ដីធ្លីនីមួយៗ។

៣-ស្នើសុំគោលការណ៍ចុះស្រាវជ្រាវ និង ស៊ើបអង្កេតដល់ទីកន្លែងកើតហេតុ ដើម្បីចងក្រងឯកសារស៊ើបអង្កេត និង ប្រមូលភស្តុតាងពាក់ពន្ធ័ទៅនឹងទំនាស់ដីធ្លី ដោយសហការជាមួយស្ថាប័នជំនាញពាក់ពន្ធ័ ព្រមទាំងអាជ្ញាធរដែនដី និង ធ្វើរបាយការណ៍ រួមទាំងធ្វើការសន្និដ្ឋានជូនថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និង សម្រេច។

៤-រៀបចំ និង បង្កើតឡើងនូវបណ្តាញស្រាវជ្រាវដែលមានលក្ខណៈជាប្រព័ន្ធ គ្រប់ជ្រុងជ្រោយ និង មានសមត្ថភាពសម្រាប់បំរើឱ្យការងារឃ្លាំមើល តាមដាន និង ប្រមូលព័ត៌មាន ។

៥-សិក្សាស្រាវជ្រាវ ប្រមូល និង ស្វែងរកព័ត៌មានពីបណ្តាញស្រាវជ្រាវរបស់ខ្លួនដែលពាក់ព័ន្ធទៅនឹងបញ្ហាទំនាស់ដីធ្លី ជាពិសេសព័ត៌មានអំពីការចោទប្រកាន់ ការឃុំខ្លួន និង អំពីពាក្យបណ្តឹងនានា ដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី។

៦-រៀបចំ និង បង្កើតឡើងនូវបែបបទ នីតិវិធី និង គោលការណ៍សំរាប់ធ្វើការវិភាគ និង វាយតំលៃព័ត៌មាន ដែលប្រមូលបានពីគ្រប់មជ្ឈដ្ឋានទាំងអស់ និង ធានាឱ្យបាននូវសុក្រឹតភាព និង សុចរិតភាពលើរបាយការណ៍ផ្លូវការ ដែលបានមកពីការស៊ើបអង្កេត។

៧-ចងក្រង និង បង្កើតឡើងជាប្រពន្ធ័គ្រប់គ្រងទិន្នន័យស្រាវជ្រាវ ឬព័ត៌មានដែលពាក់ពន្ធ័ដទៃទៀតសម្រាប់យកទៅប្រើប្រាស់ជាភស្តុតាងក្នុងការងារស៊ើបអង្កេត និង ក្នុងការចោទប្រកាន់អំពីការរំលោភ និង ទន្ទ្រានដីធ្លី ។

៨-សិក្សាស្រាវជ្រាវចងក្រងច្បាប់ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច និង លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ពន្ធ័នឹងបញ្ហាដីធ្លី ។

**ខ- អំពីការងារអធិការកិច្ច**

១-ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ បទបញ្ជា សេចក្តីសម្រេច និង លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងបញ្ហាដីធ្លី របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង ស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ ។

២-ត្រួតពិនិត្យការដោះស្រាយវិវាទដីធ្លីរបស់ស្ថាប័នពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លី ។

៣-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការងារអធិការកិច្ច ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**មាត្រា ១២.-**

**នាយកដ្ឋានទទួល និង ដោះស្រាយបណ្តឹង មានតួនាទី និង ភារកិច្ចដូចតទៅ:**

១-ទទួល និង ចុះលេខពាក្យបណ្តឹងចេញចូលតាមខេត្ត-ក្រុង និង រៀបចំកសាងសំណុំរឿង ។

២-បញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ។

៣-កោះអញ្ជើញដើមបណ្តឹង និង/ឬ ចុងចម្លើយពាក់ព័ន្ធឱ្យមកបំពេញឯកសារបន្ថែម ប្រសិនយល់ថាឯកសារមិនគ្រប់គ្រាន់ និង ធ្វើកំណត់ហេតុសួរយកចម្លើយជាបឋម ។

៤-ធ្វើចំណាត់ថ្នាក់ កំណត់អាទិភាព និង ប្រភេទវិវាទតាមវិស័យ ។

៥-ប្រមូលទិន្នន័យ និង ឯកសារបន្ថែម ដោយធ្វើទំនាក់ទំនងជាមួយភាគីជំលោះ សាក្សី រដ្ឋអំណាចមូលដ្ឋាន ក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និង អន្តរជាតិ សំរាប់ធ្វើការវិភាគអោយបានសុក្រឹត ។

៦-សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ័ ចុះពិនិត្យវាស់វែងប្លង់ និង ព្រំដីវិវាទដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ទៅតាមខ្លឹមសារនៃសំណុំរឿងវិវាទ ។

៧-រៀបចំសំណុំឯកសារវាយតំលៃ លើលទ្ធផលចុះវាស់វែង និង បញ្ជូនលទ្ធផលដំបូងខាងផ្នែកបច្ចេកទេស ដើម្បីសុំគោលការណ៍ និង សេចក្តីសំរេចពីអគ្គលេខាធិការ នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៨-ធ្វើកំណត់បង្ហាញដោយសង្ខេបខ្លឹមសារបណ្តឹង លើកអង្គហេតុ និង អង្គច្បាប់ពាក់ពន្ធ័ និង ផ្តល់យោបល់ជាបឋម ជូនថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និង សម្រេច ។

៩- ផ្ញើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលមានសុពលភាពអាចអនុវត្តបានទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធី ។

**មាត្រា ១៣.-**

**នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និង ទំនាក់ទំនងសាធារណៈ មានតួនាទី និង ភារកិច្ចដូចតទៅ:**

១- សហការជាមួយនាយកដ្ឋានរដ្ឋបាល និង បុគ្គលិក ដើម្បីរៀបចំរបាយការណ៍បូកសរុបការងារគ្រប់នាយកដ្ឋាន និង របាយការណ៍សកម្មភាពការងារផ្សេងៗទៀតរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាពិសេសកំណត់បង្ហាញ និង របាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

២- កំណត់លក្ខណៈបច្ចេកទេសកុំព្យូទ័រ បង្កើត និង អនុវត្តនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ។

៣- គ្រប់គ្រង ការពារ និង ថែទាំបណ្តាញព័ត៌មានវិទ្យា ។

៤- បណ្តុះបណ្តាលរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាដល់មន្ត្រី និង បុគ្គលិក ។

៥- ប្រមូលផ្តុំព័ត៌មាន តាមប្រព័ន្ធឃោសនាជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លី ។

៦- សហការទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ ដើម្បីផ្សព្វផ្សាយ រៀបចំ កៀងគរជំនួយក្នុងទិសដៅបំរើគោលនយោបាយរបស់អាជ្ញាធរជាតិ ។

៧- ធ្វើរបាយការណ៍លំអិតអំពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ។

៨- ធ្វើការចងក្រងព័ត៌មាន និង ធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាជាតិ និង អន្តរជាតិ រាល់ពេលប្រជុំសវនាការដោះស្រាយវិវាទ និង សកម្មភាពដោះស្រាយវិវាទទាំងឡាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

៩- សហការធ្វើសៀវភៅផ្គត់ផ្គង់បញ្ចាំងរូបភាពផ្សព្វផ្សាយអំពីការអប់រំ ទប់ស្កាត់ កុំអោយមានទំនាស់ដីធ្លីតាមសហគមន៍។

**មាត្រា ១៤.-**

**នាយកដ្ឋានរដ្ឋបាល និង បុគ្គលិក មានតួនាទី និង ភារកិច្ចដូចតទៅ:**

១-គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ។

២-កសាង និង រៀបចំលិខិតបទដ្ឋាននានារបស់អគ្គលេខាធិការដ្ឋាន និង ចរាចរលិខិតទៅគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ។

៣-កសាង និង រៀបចំគម្រោងថវិកាប្រចាំឆ្នាំ ។

៤- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និង ធ្វើបញ្ជីសារពើភណ្ឌ ។

៥-រៀបចំ និង សម្រួលកិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៦-សហការជាមួយនាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសារធារណៈ ដើម្បីធ្វើកំណត់ហេតុអង្គប្រជុំ របាយការណ៍បូកសរុបការងារគ្រប់នាយកដ្ឋាន និង របាយការណ៍សកម្មភាពការងារផ្សេងៗទៀតរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាពិសេស កំណត់បង្ហាញ និង របាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

៧-រៀបចំផែនការគ្រប់គ្រងបុគ្គលិក និង ធនធានមនុស្ស ជាពិសេសរៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យបុគ្គលិកដែលបំរើការងារមានសមត្ថភាព និង ជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៥.-**

នាយកដ្ឋាននីមួយៗត្រូវសហការគ្នា ឱ្យដំណើរការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និង ទទួលបានជោគជ័យ ។ នាយកដ្ឋាននីមួយៗ អាចស្នើសុំបង្កើតការិយាល័យមួយចំនួនតាមការចាំបាច់ ដើម្បីជាសេនាធិការ ។

## ជំពូកទី ៣
## មន្ត្រី បុគ្គលិក

**មាត្រា ១៦.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រើប្រាស់បុគ្គលិក នៃមុខងារសាធារណៈ ឬ អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ។ លក្ខខណ្ឌនៃលាភការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និង ប្រាក់បំណាច់ពិសេសសម្រាប់បើកជូនភ្នាក់ងារមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ១៧.-**

សមាជិក និង បុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្តល់មកពីអង្គការផ្តល់ជំនួយក្នុងស្រុក ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ដូចមាត្រា ១៩
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៦៦...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៨.០០០ លានរៀល ( ប្រាំបីពាន់លានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល មកជំពូក ១១ (ចំណាយដំណើរការ រដ្ឋបាល សំភារៈ និង ការជួសជុលតូច) របស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទិញបរិក្ខារពេទ្យ និង ឱសថ សំរាប់ឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

| ៥០ | - | លោកអនុសេនីយ៍ឯក | តឹក | សុគន្ធ | នាយផ្នែក នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ |
| ៥១ | - | លោកអនុសេនីយ៍ឯក | សោម | សំណាង | នាយផ្នែក នៃនាយកដ្ឋានបច្ចេកទេសព្រំដែន |
| ៥២ | - | លោកអនុសេនីយ៍ឯក | វដ្ឋ | វដ្ឋា | នាយផ្នែក នៃនាយកដ្ឋានបច្ចេកទេសព្រំដែន |
| ៥៣ | - | លោកអនុសេនីយ៍ឯក | រ៉ែម | រ៉ុម | នាយរងផ្នែក នៃនាយកដ្ឋានបច្ចេកទេសព្រំដែន |
| ៥៤ | - | លោកអនុសេនីយ៍ឯក | លាស់ | គឹមសុខ | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៥៥ | - | លោកអនុសេនីយ៍ឯក | គឹម | យិនធឿន | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៥៦ | - | លោកអនុសេនីយ៍ឯក | ជុំ | គុណ្ណាវុធ | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៥៧ | - | លោកអនុសេនីយ៍ឯក | ជូ | សារិន | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៥៨ | - | លោកអនុសេនីយ៍ឯក | យាង | គឹមលាង | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៥៩ | - | លោកស្រីអនុសេនីយ៍ឯក | ពុទ្ធ | សៅស៊ីកាំណា | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៦០ | - | លោកអនុសេនីយ៍ឯក | ហៀក | សុភក្តិ | នាយផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៦១ | - | លោកអនុសេនីយ៍ឯក | មុំ | ចេក | នាយរងផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ៦២ | - | លោកអនុសេនីយ៍ឯក | យឹម | ថាន្នី | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៣ | - | លោកអនុសេនីយ៍ឯក | ខៀវ | ចំណង់ | នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៤ | - | លោកអនុសេនីយ៍ឯក | សំ | សាមឿន | នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៥ | - | លោកអនុសេនីយ៍ឯក | សេង | ចាន់ណារី | នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៦ | - | លោកអនុសេនីយ៍ឯក | ជា | ផាន់រ៉ា | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៧ | - | លោកអនុសេនីយ៍ឯក | អ៊ុយ | ស៊ីថន | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៨ | - | លោកអនុសេនីយ៍ឯក | ឆន | សំអុល | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៦៩ | - | លោកអនុសេនីយ៍ឯក | សូ | ចាន់ប៊ុនថន | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៧០ | - | លោកអនុសេនីយ៍ឯក | សុខ | ព្រីង | អធិការ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៧១ | - | លោកអនុសេនីយ៍ឯក | អ៊ុយ | ស៊ីថា | អធិការ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៧២ | - | លោកអនុសេនីយ៍ឯក | សួន | ចន្ថា | អធិការ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៧៣ | - | លោកអនុសេនីយ៍ឯក | តៀម | សង្គ្រាម | អធិការ នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ៧៤ | - | លោកអនុសេនីយ៍ឯក | ឈួន | សិរិទ្ធ | នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ៧៥ | - | លោកអនុសេនីយ៍ឯក | យ៉ង់ | ចាន់ថន | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ៧៦ | - | លោកអនុសេនីយ៍ឯក | ព្រាប | សុផាត | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ៧៧ | - | លោកអនុសេនីយ៍ឯក | ជេត | គី | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ៧៨ | - | លោកអនុសេនីយ៍ឯក | ស្លួន | វណ្ណារ៉ា | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |

| | | | | | |
|---|---|---|---|---|---|
| ៧៩ | - | លោកអនុសេនីយ៍ឯក | ភោគ | សារិទ្ធ | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ៨០ | - | លោកអនុសេនីយ៍ឯក | តួច | ធៀម | នាយរងការិយាល័ល នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ៨១ | - | លោកអនុសេនីយ៍ឯក | កែវ | សុជាតិ | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ៨២ | - | លោកអនុសេនីយ៍ឯក | ឡាង | ប៊ុនលាង | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ៨៣ | - | លោកអនុសេនីយ៍ឯក | អឿ | សារឿន | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ៨៤ | - | លោកអនុសេនីយ៍ឯក | ឃួន | វណ្ណា | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ៨៥ | - | លោកអនុសេនីយ៍ឯក | ហ៊ី | ហ៊ីង | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ៨៦ | - | លោកអនុសេនីយ៍ឯក | ឈូង | ផាន់ | នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ៨៧ | - | លោកអនុសេនីយ៍ឯក | ខាន់ | អ៊ីង | នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ៨៨ | - | លោកអនុសេនីយ៍ឯក | ផល | វីន | នាយផ្នែក នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ៨៩ | - | លោកអនុសេនីយ៍ឯក | ហាច | ពៅ | នាយផ្នែក នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ៩០ | - | លោកអនុសេនីយ៍ឯក | ធីង | សុខុម | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩១ | - | លោកស្រីអនុសេនីយ៍ឯក | សួស | វណ្ណា | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩២ | - | លោកអនុសេនីយ៍ឯក | រឿន | សារ៉ាត់ | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៣ | - | លោកអនុសេនីយ៍ឯក | ចាន់ | ឆោម | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៤ | - | លោកអនុសេនីយ៍ឯក | ខៀវ | ប៊ុនធឿន | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៥ | - | លោកអនុសេនីយ៍ឯក | សំ | ម៉ារឌី | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៦ | - | លោកអនុសេនីយ៍ឯក | ខេន | សារឿន | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៧ | - | លោកអនុសេនីយ៍ឯក | អ៊ូម | សុវុត្ថា | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៨ | - | លោកអនុសេនីយ៍ឯក | ផាន់ | សុភាព | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ៩៩ | - | លោកអនុសេនីយ៍ឯក | មុំ | ថា | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ១០០ | - | លោកអនុសេនីយ៍ឯក | កៅ | សុលាភ | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ១០១ | - | លោកអនុសេនីយ៍ឯក | គីម | ស៊ីថា | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ១០២ | - | លោកអនុសេនីយ៍ឯក | ទី | ឡាក់ | នាយរងផ្នែក នៃនាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស |
| ១០៣ | - | លោកអនុសេនីយ៍ឯក | ខៀវ | ចាន់បូរ | នាយផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ១០៤ | - | លោកអនុសេនីយ៍ឯក | ឃុន | សុខជាតិ | នាយរងផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ១០៥ | - | លោកអនុសេនីយ៍ឯក | ទូច | វណ្ណៈ | នាយរងផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ១០៦ | - | លោកអនុសេនីយ៍ឯក | ឈិត | គីមឈុន | នាយរងផ្នែក នៃនាយកដ្ឋានស្ថាបនា |
| ១០៧ | - | លោកអនុសេនីយ៍ឯក | មាស | កាណារ៉ា | នាយរងផ្នែក នៃនាយកដ្ឋានបំភ័ន្តអក្ខរៈ |
| ១០៨ | - | លោកអនុសេនីយ៍ឯក | ញ៉េប | ជា | នាយរងផ្នែក នៃនាយកដ្ឋានសណ្តាប់ធ្នាប់ |
| ១០៩ | - | លោកអនុសេនីយ៍ទោ | ណុប | សារឿន | នាយរងផ្នែក នៃនាយកដ្ឋានសណ្តាប់ធ្នាប់ |
| ១១០ | - | លោកអនុសេនីយ៍ទោ | យឹម | ផល្លី | មន្ត្រី នៃនាយកដ្ឋានសណ្តាប់ធ្នាប់ |

| | | | | | |
|---|---|---|---|---|---|
| ១១១ | - | លោកអនុសេនីយ៍ទោ | សាយ | ដេត | អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ |
| ១១២ | - | លោកអនុសេនីយ៍ទោ | ជា | សុងដា | នាយរងប៉ុស្តិ៍ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១១៣ | - | លោកអនុសេនីយ៍ទោ | អៀង | ឧុល | មន្ត្រី នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១១៤ | - | លោកអនុសេនីយ៍ទោ | មិត្ស | ឈុន | នាយផ្នែក នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ១១៥ | - | លោកអនុសេនីយ៍ទោ | ប្រាក់ | វិគុណ | នាយផ្នែក នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ១១៦ | - | លោកអនុសេនីយ៍ទោ | គីម | ផាន | អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ១១៧ | - | លោកអនុសេនីយ៍ទោ | ជា | លាងហួរ | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ១១៨ | - | លោកអនុសេនីយ៍ទោ | ឡាច | ញឹម | នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ |
| ១១៩ | - | លោកអនុសេនីយ៍ទោ | ឌិម | សាវិន | នាយរងផ្នែក នៃស្នងការដ្ឋាននគរបាលខេតសៀមរាប |
| ១២០ | - | លោកអនុសេនីយ៍ទោ | ប៊ិច | ប៊ុនលន់ | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេតសៀមរាប |
| ១២១ | - | លោកអនុសេនីយ៍ត្រី | ថាញ់ | ប៊ុនធឿន | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ១២២ | - | លោកអនុសេនីយ៍ត្រី | ឃុត | សំបូរ | មន្ត្រី នៃនាយកដ្ឋានសណ្តាប់ធ្នាប់ |
| ១២៣ | - | លោកអនុសេនីយ៍ត្រី | គីម | សំបូរ | មន្ត្រី នៃនាយកដ្ឋានសណ្តាប់ធ្នាប់ |
| ១២៤ | - | លោកអនុសេនីយ៍ត្រី | សុខ | ទីន | មន្ត្រី នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១២៥ | - | លោកអនុសេនីយ៍ត្រី | ខឹម | សុខន | នាយរងប៉ុស្តិ៍ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១២៦ | - | លោកអនុសេនីយ៍ត្រី | ប៉ាល់ | ម៉ាត់ | នាយរងប៉ុស្តិ៍ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១២៧ | - | លោកអនុសេនីយ៍ត្រី | ហែម | ធៀង | នាយរងផ្នែក នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១២៨ | - | លោកអនុសេនីយ៍ត្រី | អ៊ុំ | ចេន | នាយរងផ្នែក នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១២៩ | - | លោកអនុសេនីយ៍ត្រី | ខៃ | គីប | មន្ត្រី នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១៣០ | - | លោកអនុសេនីយ៍ត្រី | ថោង | វណ្ណឌី | នាយរងផ្នែក នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ១៣១ | - | លោកអនុសេនីយ៍ត្រី | កាំង | សុក្ខុង | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ១៣២ | - | លោកព្រិន្ទបាលឯក | សោម | ភារុណ | នាយរងប៉ុស្តិ៍ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១៣៣ | - | លោកព្រិន្ទបាលឯក | ហោ | សុធា | នាយរងផ្នែក នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១៣៤ | - | លោកព្រិន្ទបាលឯក | មួន | សារួន | មន្ត្រី នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១៣៥ | - | លោកព្រិន្ទបាលឯក | នូ | សុភ័ក្រពណ្ណារា | នាយរងផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៣៦ | - | លោកព្រិន្ទបាលឯក | ថោង | សាឡាប | មន្ត្រី នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ១៣៧ | - | លោកព្រិន្ទបាលទោ | ឌៀង | អ៊ិត | មន្ត្រី នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១៣៨ | - | លោកព្រិន្ទបាលទោ | ផាត់ | សារឿន | មន្ត្រី នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ១៣៩ | - | លោកពលបាលឯក | ឈិត | ផុន | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| ១៤០ | - | លោកពលបាលទោ | ស៊ុន | តាំងលី | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤១ | - | លោកពលបាលទោ | ចាង | កុមា | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤២ | - | លោកពលបាលទោ | សៀង | ម៉ារ៉ា | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |

| | | | | | |
|---|---|---|---|---|---|
| ១៤៣ | - | លោកពលបាលទោ | ប៊ុរិន | ណារឿន | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤៤ | - | លោកពលបាលទោ | ម៉ែត | សុខបំណង | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤៥ | - | លោកពលបាលទោ | នាក់ | សុខាន់ | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤៦ | - | លោកពលបាលទោ | ព្រំ | ធីរិទ្ធ | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤៧ | - | លោកពលបាលទោ | ខន | សុខឿន | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤៨ | - | លោកពលបាលទោ | នុត | ផាយមុនី | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៤៩ | - | លោកពលបាលទោ | ឈួន | ចាន់ថុន | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |
| ១៥០ | - | លោកពលបាលទោ | អ៊ុក | ចន្ថា | មន្ត្រី នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ១៥១ | - | លោកពលបាលទោ | ហៃន | ពុជ | មន្ត្រី នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន |
| ១៥២ | - | លោកពលបាលទោ | ហាក់ | ច័ន្ទដារិទ្ធ | មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី |

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :***
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា២*

*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤១៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការដាក់មន្ត្រីរាជការ
## ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា១** : ត្រូវបានដាក់មន្ត្រីរាជការ ចំនួន ០២ រូប ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម :

១- លោក **ជិម លន់** វរមន្ត្រី ថ្នាក់លេខ ២ ប្រធានមន្ទីរ ចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦ នេះតទៅ ។

២- លោក **ស៊ុន ចាន់ថុល** វរមន្ត្រី ថ្នាក់លេខ ៣ អនុប្រធាននាយកដ្ឋាន ចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ នេះតទៅ ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៩៧ អនក្រ.តត**

# អនុក្រឹត្យ

# ស្តីពី

# ការតែងតាំងក្រុមប្រឹក្សាភិបាល

# អគ្គិសនីកម្ពុជា អាណត្តិទី ៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦ ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាមួយក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

# ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជាអាណត្តិទី ៤ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១_លោក | **កែវ រតនៈ** | អគ្គនាយករងឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| ២_ឯកឧត្តម | **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៣_ឯកឧត្តម | **តាន់ គិមវិន់** | អគ្គនាយក អគ្គិសនីកម្ពុជា |
| ៤_ឯកឧត្តម | **ហែម ក្រាញ់ តូនី** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ |
| ៥_លោក | **គី ខេមលីន** | អនុប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ នៃក្រសួងយុត្តិធម៌ |
| ៦_កញ្ញា | **សុខ សុទ្ធារី** | ប្រធានរដ្ឋបាលសភាពាណិជ្ជកម្ម រាជធានីភ្នំពេញ |
| ៧_លោក | **កែវ វីរៈ** | តំណាងនិយោជិត កម្មករ អគ្គិសនីកម្ពុជា |

**មាត្រា ២ :** ប្រធានក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាភិបាល ក្នុងចំណោមសមាជិកទាំងនោះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤៩៣...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

### សម្រេច

**មាត្រា ១:** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឡុង ខុង** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងធនធានទឹក និងឧតុនិយម ដោយរក្សាក្របខ័ណ្ឌ និងឋានន្តរស័ក្តិដដែល ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល ផ្លាស់ប្តូរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **ខៀវ សំអាត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលស្រុកកៀនស្វាយ ឱ្យទៅបំរើការងារនៅសាលាខេត្តកណ្តាល ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា ២ :** ត្រូវបានផ្លាស់ប្តូរភារកិច្ចលោក **គុណ សំអុល** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលស្រុកលើកដែក ឱ្យទៅជាអភិបាលស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**មាត្រា ៣ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ថាច់ សុវណ្ណ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងបរិស្ថាន ជាអភិបាលស្រុកលើកដែក ខេត្តកណ្តាល ។

**មាត្រា ៤ :** លោក **ថាច់ សុវណ្ណ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*(ដើម្បីជូនជ្រាប)*
*ដូចមាត្រា ៦ (ដើម្បីអនុវត្ត)*
*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៤៩៥...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៙
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៧គ្រឿង ប្រគេន និងជូនសប្បុរសជន នៅក្នុង និងក្រៅប្រទេស ដែលបានចូលរួមជួយកសាង កុដិ ខ្លោងទ្វារវត្ត សាលាពុទ្ធិកបឋមសិក្សា និង ស្ពានស្រះទឹក នៅក្នុង វត្តសំរោងពេជ្រ ឃុំស្វាយធំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សរុបទឹកប្រាក់ ចំនួន ៤២.០០០ ដុល្លារ ដូចមាន រាយព្រះនាម និងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ភិក្ខុ **កែន សុខ** ព្រះចៅអធិការវត្ត សំរោងពេជ្រ

២-លោក **ឆាយ សាន្ត**

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ពៅ សារ៉ាត់** ប្រធានគណៈកម្មការទ្រទ្រង់ និង កសាងវត្តសំរោងពេជ្រ

២-លោកស្រី **មូល ផេង** សប្បុរសជន នៅប្រទេសបារាំង

៣-លោកអាចារ្យ **សុខ ទំរ** ប្រធានអាចារ្យ វត្តសំរោងពេជ្រ

៤-លោក **ហ៊ុយ គីមហ៊ួ** អនុប្រធានគណៈកម្មការ កសាងវត្តសំរោងពេជ្រ

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

-ភិក្ខុ **ខួន ខុត** គ្រូសូត្រស្តាំ វត្តសំរោងពេជ្រ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្ត អនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៧០...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចម្រុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធពេលអនុវត្តសេចក្តីសម្រេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការចម្រុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធពេលអនុវត្តសេចក្តីសម្រេចរបស់តុលាការ បង្កឱ្យមានស្លាប់ និងរបួសដល់ប្រជាពលរដ្ឋ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ជាប្រធាន

២- ឯកឧត្តម **ហ៊ុន តៀវ** រដ្ឋលេខាធិការ ក្រសួងការពារជាតិ ជាអនុប្រធាន

៣- ឯកឧត្តម **ឱូត លុច** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជាអនុប្រធាន

៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ ជាសមាជិក

៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

៦- ឯកឧត្តម **គុល ធីរត្ន** អគ្គាធិការរង ក្រសួងមហាផ្ទៃ ជាសមាជិក

៧- ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យ ជាសមាជិក

**ប្រការ២ :** គណៈកម្មការចម្រុះអន្តរក្រសួងមានភារកិច្ច :

- ស្រាវជ្រាវ ស៊ើបអង្កេតរកឱ្យឃើញកងកំលាំងប្រដាប់អាវុធ ឬមន្ត្រីរាជការណា ដែលជាអ្នកដៃដល់ និងជាអ្នកសមគំនិតក្នុងហេតុការណ៍ផ្ទុះអាវុធបណ្តាលឱ្យប្រជាពលរដ្ឋស្លាប់ចំនួន ០៥ នាក់ និងរបួសចំនួន ០៧ នាក់ ក្នុងពេលដែល កំលាំងចំរុះចុះអនុវត្តដីកាសម្រេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥
- ចាត់វិធានការ និងដាក់វិន័យរដ្ឋបាលចំពោះជនដៃដល់ និងអ្នកសមគំនិតទាំងអស់ រួចហើយកសាង និងបញ្ជូនសុំណុំរឿងទៅតុលាការ ដើម្បីចាត់ការតាមច្បាប់ជាធរមាន
- រាយការណ៍អំពីលទ្ធផលដែលសម្រេចបាន តាមជំហានីមួយៗជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣ :** អនុប្រធាន និង សមាជិកគណៈកម្មការចម្រុះអន្តរក្រសួងត្រូវចូលរួមប្រជុំ និងចូលរួមបំពេញភារកិច្ចតាមការអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ៤ :** គណៈកម្មការចម្រុះអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។ ក្នុងករណីចាំបាច់ គណៈកម្មការចំរុះអន្តរក្រសួងអាចបង្កើតអនុគណៈកម្មការ ឬក្រុមការងារជំនាញ ដើម្បីជួយក្នុងកិច្ចការស្រាវជ្រាវនេះ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ ប្រធានស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧១ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ និងស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** បង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យរដ្ឋមួយនៅខេត្តបាត់ដំបង ដែលមាន សមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ប្រាជ្ញ ចន្ទ** | អភិបាលខេត្តបាត់ដំបង | ប្រធាន |
| ២- | ឯកឧត្តម **អ៊ុយ ស៊ីម** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** | អនុប្រធាន |
| ៣- | ឯកឧត្តម **ចាន់ ណារ៉ាវិត** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | អនុប្រធាន |
| ៤- | ឯកឧត្តម **មាស សារីម** | ជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** | សមាជិក |
| ៥- | ឯកឧត្តម **ជា អឿន** | អគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- | លោក **ម៉ក់ ឌីយ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

៧- លោក **ឡាយ ប៊ុរិន** ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨- លោក **យូ ទីរៈ** អនុប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៩- លោក **ម៉ៅ ម៉ើ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង សមាជិក

១០- លោក **ខួន រតនៈ** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង សមាជិក

១១- លោក **ទៅ ប្រុង** នាយកខុទ្ទកាល័យសាលាខេត្តបាត់ដំបង សមាជិកអចិន្ត្រៃយ៍

**ប្រការ ២.-** គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- សិក្សា និងលើកគំរោងនៃសំណង់អាគារសិក្សា និងចាត់ចែងការសាងសង់
- ចាត់ចែង គ្រប់គ្រងសំភារៈសំណង់ និងត្រួតពិនិត្យការសាងសង់
- ចាត់ចែង និងត្រួតពិនិត្យការបំពាក់គ្រឿងបង្គំនៃសំណង់ និងគ្រឿងសង្ហារឹមនានា
- បំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ត្រូវរាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងារ ។

**ប្រការ ៣.-** សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- សាលាខេត្ត ក្រុងពាក់ព័ន្ធ
- ដូចចែងក្នុងប្រការ ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦

# ប្រកាស
## ស្តីពី
## នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្របក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញប្រកាសលេខ ៤៨៧ ឧរថ.បល.ប្រក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- តាមសំណូមពរចាំបាច់របស់ក្រសួង

# សម្រេច

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- ការកំណត់លក្ខណៈរបស់ប្រកាស**

ប្រកាសនេះត្រូវចាត់ទុកជាបទបញ្ជានៃការអនុវត្តន៍ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មអនុលោមតាមមាត្រា ១៣០ នៃ ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរ ឧស្សាហកម្ម ។

**ប្រការ ២.- ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី**

នាយកដ្ឋានទទួលចុះបញ្ជីត្រូវ ទទួល ពិនិត្យសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម និង ចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីការពារកម្មសិទ្ធិបញ្ញារបស់អ្នកបង្កើតស្នាដៃគំនូរឧស្សាហកម្ម អនុលោមតាមច្បាប់ ។

**ប្រការ ៣.- ការបកស្រាយ**

នៅក្នុងប្រកាសនេះពាក្យដូចខាងក្រោមត្រូវបានបកស្រាយ :

-**ច្បាប់** គឺច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ។

- **រដ្ឋមន្ត្រី** គឺរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

- **មន្ត្រីកាន់កាប់បញ្ជី** គឺប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** គឺនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

- **អនុសញ្ញាទីក្រុងប៉ារីស** គឺអនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីសស្តីពីការការពារ កម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ហើយបានកែសម្រួលចុងក្រោយ ។

-**សំណុំលិខិតស្នើសុំដំបូង** គឺជាសំណុំលិខិតស្នើសុំដែលបានដាក់មុន ឬបានសុំចុះបញ្ជីមុន ។

## ផ្នែកទី ២

## នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

**ប្រការ ៤.- ចំណាត់ថ្នាក់នៃគំនូរឧស្សាហកម្ម**

មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងទីក្រុងឡូកាណូ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៦៨ ហើយបានកែសម្រួលបោះពុម្ពជាបន្តបន្ទាប់ សម្រាប់បម្រើគោលបំណងពាក់ពន្ធ័នឹងការចុះបញ្ជី និងការបោះពុម្ពផ្សាយគំនូរឧស្សាហកម្ម ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវរកឯកសារដែលបានរក្សាទុកតាមចំណាត់ថ្នាក់។

**ប្រការ ៥.- សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម**

សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោមៈ-

១-អនុលោមតាមមាត្រា ៩៥ នៃច្បាប់ សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មដែលរួមមាន ពាក្យសុំ គំនូសបង្ហាញ រូបថត ឬគំនូសតាងសមស្របផ្សេងៗទៀត ជាតំណាងនៃវត្ថុដែលបង្កើតឡើងពីគំនូរឧស្សាហកម្ម និងការចង្អុលបង្ហាញប្រភេទផលិតផលដែលគំនូរឧស្សាហកម្មត្រូវបានយកមកប្រើប្រាស់ ត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ហើយត្រូវបង់កម្រៃ តាមការកំណត់ ។

២-ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំលេខ **១គឧ** ដែលមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធ ក** នៃប្រកាសនេះ ។

៣-សំណុំលិខិតស្នើសុំត្រូវបញ្ជាក់អំពី ឈ្មោះ អសយដ្ឋាន សញ្ជាតិ ទីលំនៅ របស់អ្នកដាក់ពាក្យសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ។

៤-ក្នុងករណីអ្នកដាក់ពាក្យសុំជាអ្នកបង្កើតស្នាដៃ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ ហើយក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនមែនជាអ្នកបង្កើតស្នាដៃទេនោះ ពាក្យសុំត្រូវមានបញ្ជាក់អំពីឈ្មោះ និងអសយដ្ឋានរបស់អ្នកបង្កើតស្នាដៃ ពោលគឺអ្នកគូសគំនូរឧស្សាហកម្មម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយ នូវឯកសារដែលបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ចំពោះការចុះបញ្ជីគំនូរឧស្សាហកម្ម ។

៥-ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ ពាក្យសុំត្រូវបញ្ជាក់ផងដែរអំពីឈ្មោះ និងអសយដ្ឋានរបស់ភ្នាក់ងារនោះ ។

៦-ការស្នើសុំដោយអ្នកដាក់ពាក្យសុំសម្រាប់ពន្យារពេលនៃការបោះពុម្ពផ្សាយគំនូរ

ឧស្សាហកម្ម ឬគំនូរដែលមាននៅក្នុងសំណុំលិខិតស្នើសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់អំពីរយៈពេល នៃការសុំពន្យារនោះ ។

**ប្រការ ៦.- ចំនួន ទំហំនៃក្រាហ្វិចតាង និង រូបសំណាកតាងឱ្យរូបពិត**

ចំនួន និងទំហំនៃក្រាហ្វិចតាង និងរូបសំណាកតាងឱ្យរូបពិត ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោមៈ-

១.សំណុំលិខិតស្នើសុំត្រូវតែភ្ជាប់មកជាមួយនូវ :

ក-ក្រាហ្វិចតាង ចំនួនបួន(៤)ច្បាប់ ឬគំនូសបង្ហាញ ឬគំនូសផ្ទាប់ចម្លងតាមចំនួន(៤)ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មជាទម្រង់ពីរខ្នាត ឬ

ខ-ក្រហ្វិចតាង ចំនួនបួន(៤)ច្បាប់ ឬគំនូសបង្ហាញ ឬគំនូសចម្លងតាម នៃផ្នែកខុសៗគ្នានីមួយៗរបស់គំនូរឧស្សាហកម្ម ចំនួនបួន(៤)ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មជាទម្រង់បីខ្នាត និង

គ-គំនូរបោះពុម្ពនៅលើសន្លឹកក្រដាសដែលមិនត្រូវមានខ្នាតធំលើសពីទំហំ ១៧,០ស.ម X ២៦,២ស.ម ឡើយ ។

២.រូបសំណាកតាងឱ្យរូបពិតរបស់គំនូរឧស្សាហកម្មមិនត្រូវមានខ្នាតធំលើសពីទំហំ ២០ស.ម X ២០ស.ម X ២០ស.ម ឡើយ ។ ក្រាហ្វិចតាង គំនូសបង្ហាញ ឬគំនូសចម្លងតាមនៃគំនូរឧស្សាហកម្មមិនត្រូវមានខ្នាតធំលើសពីទំហំ ១០ស.ម X ២០ស.ម ឡើយ ។ គំនូសតាង គំនូសបង្ហាញ ឬគំនូសចម្លងតាមទាំងនោះត្រូវគូសនៅលើក្រដាសក្រាស់រឹង ដែលមានទំហំអា៤ ចំនួនបួន(៤)សន្លឹក ។ គំនូសបង្ហាញ និងគំនូសចម្លងតាម ត្រូវគូសដោយទឹកខ្មៅពណ៌ខ្មៅ ។

**ប្រការ ៧.- ភាសានៃឯកសារ និងការបកប្រែ**

ភាសានៃឯកសារ និងការបកប្រែ ត្រូវអនុវត្តដូចខាងក្រោមៈ-

១.សំណុំលិខិតស្នើសុំ និងឯកសារណាមួយដែលបង្កើតបានជាផ្នែកមួយ នៃសំណុំលិខិតស្នើសុំ ឬឯកសារណាមួយបានដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ឬមន្ត្រីកាន់កាប់បញ្ជីអនុលោមតាមច្បាប់ ប្រកាសនេះ និងបទបញ្ញាពាក់ព័ន្ធត្រូវធ្វើជាភាសាខ្មែរ ។

២.សម្រាប់គោលបំណងនៃការស្រាវជ្រាវ និងការពិនិត្យ ក្នុងករណីសំណុំលិខិតស្នើសុំ និងឯកសារដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ដែលបានសរសេរជាភាសាខ្មែរ ឬជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាអង់គ្លេស ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេលប្រាំមួយ (៦) ខែគិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី ។

៣.សម្រាប់គោលបំណងនៃការវិនិច្ឆ័យ ការការពារ និងការអនុវត្តនីច្បាប់ ក្នុង

ករណី សំណុំលិខិតស្នើសុំដែលសរសេរជាភាសាបរទេសក្រៅពីភាសាខ្មែរ ត្រូវបកប្រែជាភាសាខ្មែរ ហើយ ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេលប្រាំមួយ (៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី ។

**ប្រការ ៨.- ការបញ្ជាក់ឈ្មោះ សញ្ជាតិ អសយដ្ឋាន និងលំនៅដ្ឋាន**

ការបញ្ជាក់ឈ្មោះ អសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋាន ត្រូវបញ្ជាក់ដូចខាងក្រោមៈ-

១-ត្រង់ចំណុចឈ្មោះរបស់រូបវន្តបុគ្គលត្រូវបញ្ជាក់ដោយ នាមត្រកូល នាមខ្លួន សញ្ជាតិ និង អសយដ្ឋាន របស់បុគ្គលនោះ ។ ឈ្មោះរបស់នីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញជាផ្លូវការរបស់នីតិបុគ្គលនោះ ។

២-ត្រង់ចំណុចសញ្ជាតិត្រូវបញ្ជាក់ឈ្មោះប្រទេសដែលបុគ្គលនោះជាជនជាតិ ។ នីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះប្រទេសដែលនីតិបុគ្គលនោះត្រូវបានបង្កើតនៅក្រោមច្បាប់នៃប្រទេសនោះ ព្រមទាំងការិយាល័យដែលបានចុះបញ្ជីរួចហើយរបស់នីតិបុគ្គលនោះ ។

៣-ត្រង់ចំណុចអសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់តាមវិធីណាមួយដើម្បីបំពេញការតម្រូវជាធម្មតា សម្រាប់ការបញ្ជូនតាមប្រៃសណីយ៍បានឆាប់ទៅដល់អសយដ្ឋានដែលបញ្ជាក់នោះ ហើយក្នុងករណីណាមួយក៏ដោយ ក៏ត្រូវបញ្ជាក់ផងដែរនូវអង្គភាពរដ្ឋបាលពាក់ព័ន្ធរួមទាំងលេខផ្ទះ ប្រសិនបើមាន ។ អសយដ្ឋានត្រូវមានបញ្ជាក់ លេខទូរស័ព្ទ លេខទូរសារ និងអសយដ្ឋាន អ៊ីម៉ែលផងដែរ ។

៤-ត្រង់ចំណុចលំនៅដ្ឋានត្រូវបានបញ្ជាក់ឈ្មោះប្រទេស ដែលបុគ្គលនោះជាជនមានលំនៅដ្ឋានជាប់លាប់ ។

៥-គ្រប់អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវផ្តល់ឱ្យមន្ត្រីកាន់កាប់បញ្ជីនូវអសយដ្ឋានសម្រាប់ទំនាក់ទំនងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងនៃសំណុំលិខិតស្នើសុំរបស់គាត់ ។

**ប្រការ ៩.- ការប្តូរឈ្មោះ សញ្ជាតិ និងអសយដ្ឋាន**

ការប្តូរឈ្មោះ សញ្ជាតិ និងអសយដ្ឋាន ត្រូវអនុវត្តដូចខាងក្រោមៈ-

១-សំណើសុំដោយម្ចាស់ ឬដោយអ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីប្តូរឈ្មោះ សញ្ជាតិ អសយដ្ឋាន ឬអសយដ្ឋានសម្រាប់ទាក់ទងដែលបានកត់ត្រាចំពោះគំនូរឧស្សាហកម្ម ឬនៅក្នុងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មរបស់ខ្លួន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-មុននឹងអនុវត្តតាមសំណើក្នុងការប្តូរឈ្មោះ ឬសញ្ជាតិ មន្ត្រីកាន់កាប់បញ្ជីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំ ផ្តល់ភស្តុតាងសមស្របពាក់ព័ន្ធទៅនឹងការប្តូរនេះ ។

៣~ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណើនោះសមស្រប មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តការប្ដូរនោះលើគំនូរឧស្សាហកម្ម ឬក៏លើសំណុំលិខិតស្នើសុំការចុះបញ្ជីគំនូរឧស្សាហកម្ម ហើយក្នុងករណីដែលឈ្មោះ សញ្ជាតិ ឬអសយដ្ឋាន ត្រូវបានកត់ត្រារួចហើយនៅក្នុងបញ្ជី បញ្ជីនោះក៏ត្រូវតែកត់ត្រាការប្ដូរនោះឱ្យបានត្រឹមត្រូវ ។

**ប្រការ ១០.~ ការចុះហត្ថលេខា**

ការចុះហត្ថលេខាត្រូវអនុវត្តដូចខាងក្រោមៈ-

១~ ឯកសារដែលរៀបចំដើម្បីចុះហត្ថលេខាជូសមុខឱ្យ ឬក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ក្រុមហ៊ុន និងដៃគូទាំងអស់ ជាឈ្មោះពេញ ហើយត្រូវបានចុះហត្ថលេខា ដោយអ្នកទាំងអស់នោះ ឬដោយដៃគូណាមួយ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចុះហត្ថលេខា ដោយបញ្ជាក់ថា ដៃគូនោះចុះហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬចុះហត្ថលេខា ដោយបុគ្គលណាម្នាក់ផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ ។ ឯកសារដែលបានរៀបចំដើម្បីចុះហត្ថលេខាជូសមុខឱ្យ ឬក្នុងនាមអង្គភាពសាជីវកម្ម ត្រូវចុះហត្ថលេខាដោយនាយក ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ណាមួយផ្សេងទៀត របស់អង្គភាពសាជីវកម្មនោះ ឬដោយបុគ្គលណាមួយផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ និងប្រថាប់ត្រារបស់អង្គភាពសាជីវកម្មនោះផង ។ ឯកសារដែលរៀបចំឡើងដើម្បីចុះហត្ថលេខាជូសមុខឱ្យ ឬក្នុងនាមសមាគមនៃបុគ្គលច្រើននាក់ អាចត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ។

២~ ក្នុងករណីដែលយល់ថាចាំបាច់ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើសុំឱ្យផ្ដល់ភស្តុតាងនៃការអនុញ្ញាតឱ្យចុះហត្ថលេខា ។

**ប្រការ ១១.~ ការប្រកាសអាទិភាព**

ការប្រកាសដែលអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម យោងតាមមាត្រា ១០០ នៃច្បាប់ ត្រូវអនុវត្តដូចខាងក្រោមៈ-

១~សេចក្ដីប្រកាសដែលបានអះអាងយោងតាមមាត្រា ២៧ នៃច្បាប់ ត្រូវធ្វើឡើងនៅពេលដាក់សំណុំលិខិតស្នើសុំគំនូរឧស្សាហកម្ម ហើយត្រូវបញ្ជាក់អំពី :

ក-កាលបរិច្ឆេទនៃការសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដំបូង ។

ខ-លេខនៃសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ២ នៃប្រការនេះ ។

គ-និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលត្រូវបានដាក់ចំពោះសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ៣ នៃប្រការនេះ ។

ឃ-ឈ្មោះប្រទេសដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំដំបូង ឬឈ្មោះប្រទេសមួយឬច្រើន ដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំនោះ ក្នុងករណីដែលសំណុំលិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ ។

ង-ឈ្មោះការិយាល័យដែលបានទទួលការសុំចុះបញ្ជីនៃ សំណុំលិខិតស្នើសុំដំបូង ក្នុងករណីសំណុំលិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ ។

២~ក្នុងករណីនាពេលដាក់សេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រកាសនេះ លេខនៃសំណុំលិខិតស្នើសុំដំបូង មិនត្រូវបានដឹងទេនោះ លេខនេះត្រូវតែផ្តល់ឱ្យក្នុងរយៈពេល បី(៣)ខែ ក្រោយកាលបរិច្ឆេទនៃការដាក់សំណុំលិខិតស្នើសុំ នៅនាយកដ្ឋានចុះបញ្ជីអាទិភាពនោះត្រូវបានសុំចុះបញ្ជី ។

៣~ក្នុងករណីនាពេលដាក់សេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រកាសនេះ និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិ នៃគំនូរឧស្សាហកម្ម មិនត្រូវបានកំណត់ឱ្យចំពោះសំណុំលិខិតស្នើសុំដំបូង ឬមិនទាន់បានកំណត់ឱ្យនៅឡើយ អ្នកដាក់ពាក្យសុំ ត្រូវថ្លែងបញ្ជាក់អំពីហេតុការណ៍នេះនៅក្នុងសេចក្តីប្រកាសនោះ ហើយត្រូវផ្តល់និមិត្តសញ្ញានេះយ៉ាងឆាប់ខណៈដែលវាត្រូវបានកំណត់ ។

៤~អ្នកដាក់ពាក្យសុំអាចកែតម្រូវអត្ថបទនៃសេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រកាសនេះ នាពេលណាមួយមុនការចុះបញ្ជីគំនូរឧស្សាហកម្ម ។

៥~យោងតាមមាត្រា ២៨ នៃច្បាប់ រយៈពេលសម្រាប់ការផ្តល់ឯកសារចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើមនៃសំណុំលិខិតស្នើសុំដំបូង ត្រូវមានរយៈពេល បី(៣) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំដោយមន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណី ដែលឯកសារចម្លងនៃសំណុំលិខិតស្នើសុំត្រូវបានប្រគល់រួចហើយ សម្រាប់ការដាក់សំណុំលិខិតស្នើសុំផ្សេងទៀត អ្នកដាក់ពាក្យសុំអាចឆ្លើយតប ដោយធ្វើសេចក្តីយោងទៅលើការដាក់សំណុំ លិខិតស្នើសុំផ្សេងទៀតនោះ ។

៦~ក្នុងករណីសំណុំលិខិតស្នើសុំដំបូង សរសេរជាភាសាផ្សេងក្រៅពីភាសាខ្មែរ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែនៃសំណុំលិខិតស្នើសុំនោះ ជាភាសាខ្មែរ ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី ។

៧~ទោះបីជាគ្មានការស្នើសុំពីមន្ត្រីកាន់កាប់បញ្ជីក៏ដោយ ក៏អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ឱ្យនូវសំណុំលិខិតស្នើសុំដំបូង ចំនួនមួយ(១)ច្បាប់ ជាមួយសេចក្តីបកប្រែសំណុំលិខិតនោះ

ចំនួនមួយ(១)ច្បាប់ ។

**ប្រការ ១២.- ការដកហូតយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ**

ការដកហូតយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ ត្រូវអនុវត្តដូចខាងក្រោមៈ-

១.សំណុំលិខិតស្នើសុំត្រូវសុំដកយកវិញបាន ដោយសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ។

២.កម្រៃពាក់ព័ន្ធនឹងការដាក់សំណុំលិខិតស្នើសុំមិនត្រូវបានប្រគល់ឱ្យវិញទេ ប្រសិនបើសំណុំលិខិតស្នើសុំ ត្រូវបានដកយកទៅវិញ ។

៣.ការកែតម្រូវណាមួយ នៃសំណុំលិខិតស្នើសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

៤.សំណុំលិខិតស្នើសុំគំនូរឧស្សាហកម្មដែលត្រូវបានដកហូតយកទៅវិញ បានបោះបង់ចោល ឬត្រូវបានបដិសេធ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ៤(គ)(៤) ស្តីពីសិទ្ធិអាទិភាពនៃអនុសញ្ញាក្រុងប៉ារីស តាមការសមស្រប ។

**ប្រការ ១៣.- ការចុះលេខ និងការគូសសញ្ញា**

ការចុះលេខ និងការគូសសញ្ញា ត្រូវអនុវត្តដូចខាងក្រោមៈ-

១.នៅពេលទទួលសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់នៅលើឯកសារនីមួយៗនៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួល និងលេខសំណុំលិខិតស្នើសុំ ដែលផ្តុំដោយអក្សរ "**KH**" បន្ទាត់ទ្រេត"/" អក្សរ "**ID**" បន្ទាត់ទ្រេត"/" លេខពីរខ្ទង់ចុងក្រោយនៃឆ្នាំដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត"/" និងលេខចំនួនប្រាំខ្ទង់ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល ។ ក្នុងករណីដែលឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ត្រូវបានទទួលនៅលើកាលបរិច្ឆេទខុសគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់ផងដែរ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនោះនៅកន្លែងសមស្របរបស់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម (គំរូពាក្យសុំលេខ **១ID**) ។

២.លេខសំណុំលិខិតស្នើសុំដែលមានចែងក្នុងចំណុចទី១ នៃប្រការនេះ ត្រូវស្រង់យកមកដាក់នៅក្នុងការទាក់ទងពត៌មាន តាមលំដាប់លំដោយពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ ។

**ប្រការ ១៤.- ការពិនិត្យ**

បន្ទាប់ពីអនុវត្តតាមការចែងក្នុងប្រការ ១៣ នៃប្រកាសនេះរួចហើយ ត្រូវអនុវត្តបន្តដូចខាងក្រោមៈ-

១.មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យថា តើសំណុំលិខិតស្នើសុំ បំពេញត្រឹមត្រូវតាមការ

តម្រូវរបស់មាត្រា ៩៥ នៃច្បាប់ប្តូទេ ។

២-ការអញ្ជើញឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវណាមួយតាមវាក្យខណ្ឌទី ២ នៃមាត្រា១០១ នៃច្បាប់ រួមជាមួយគ្នា និងមាត្រា ៣៤ នៃច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។ ការអញ្ជើញ ត្រូវមានបញ្ជាក់អំពីការកែតម្រូវ ឬការតម្រូវឱ្យកែ ហើយស្នើឱ្យដាក់ពាក្យសុំធ្វើការកែតម្រូវនោះ ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញនោះ ។

៣-នៅពេលយល់ព្រមលើកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ។ ប្រសិនបើសំណុំលិខិតស្នើសុំត្រូវបានចាត់ទុកថាមិនត្រូវទទួលចុះបញ្ជី ដូចមានចែងក្នុងមាត្រា ១០១ នៃច្បាប់ រួមជាមួយគ្នា និងមាត្រា ៣៤ នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយមានបញ្ជាក់ពីមូលហេតុផង ។

៤-ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា ៨៩ មាត្រា ៩០ មាត្រា ៩៣ មាត្រា ៩៥ និង មាត្រា ៩៦ នៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយពាក់ពន្ធ័នឹងមាត្រាទាំងនេះ មិនបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរធ្វើការកែតម្រូវ ដែលបានតម្រូវក្នុងរយៈពេល ពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ជាមួយនឹងការបង់កម្រៃតាមការកំណត់ ។ ប្រសិនបើអ្នកដាក់ពាក្យសុំ មិនបានអនុវត្តត្រឹមត្រូវ តាមការអញ្ជើញឱ្យធ្វើការកែតម្រូវនូវកំហុស ដែលមាននៅក្នុងសំណុំលិខិតស្នើសុំទេនោះ ឬថ្វីបើអ្នកដាក់ពាក្យសុំបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជីនូវការកែតម្រូវរួចហើយក៏ដោយ ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាល័ក្ខខ័ណ្ឌខាងលើ មិនត្រូវបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយបញ្ជាក់អំពីមូលហេតុផង ។

៥-ការបដិសេធសំណុំលិខិតស្នើសុំ មិនមានឥទ្ធិពលដល់កាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ ដែលនៅតែរក្សាសុពលភាពដដែល ។

៦-មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យសុំអំពីការសម្រេចយល់ព្រមចុះបញ្ជី ឬអំពីការសម្រេចបដិសេធសំណុំលិខិតស្នើសុំ ហើយក្នុងករណីដែលសម្រេចចុះបញ្ជីសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំបង់កម្រៃក្នុងការចុះបញ្ជី ក្នុងរយៈពេលមួយ(១)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង ។

**ប្រការ ១៥.- ការចុះបញ្ជីគំនូរឧស្សាហកម្ម**

ការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោមៈ-

១.-អាស្រ័យដោយការបង់កម្រៃក្នុងការចុះបញ្ជី តាមរយៈពេលដែលបានកំណត់ក្នុងចំណុច ៦ នៃប្រការ ១៤ នៃប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចុះបញ្ជីគំនូរឧស្សាហកម្មនោះ ស្របតាមមាត្រា១០៣ នៃច្បាប់ និងប្រកាសនេះ ។

២.-មន្ត្រីកាន់កាប់បញ្ជីត្រូវចុះលេខសម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្មនីមួយៗ ទៅតាមលំដាប់លំដោយនៃការចុះបញ្ជី ។

៣.-ការចុះបញ្ជីគំនូរឧស្សាហកម្មត្រូវរួមបញ្ចូលការបង្ហាញអំពីគំនូរឧស្សាហកម្ម និងត្រូវបញ្ជាក់អំពី :

ក- លេខនៃគំនូរឧស្សាហកម្ម

ខ- ឈ្មោះ និងអសយដ្ឋានរបស់ម្ចាស់ ដែលបានចុះបញ្ជីរួចហើយ

គ-ឈ្មោះ និងអសយដ្ឋានរបស់ភ្នាក់ងារតំណាង ប្រសិនបើមាន

ឃ-ឈ្មោះ និងអសយដ្ឋានរបស់អ្នកបង្កើត លើកលែងតែករណីដែលអ្នកបង្កើតស្នើសុំ មិនឱ្យដាក់ឈ្មោះរបស់គេក្នុងការចុះបញ្ជី

ង-ប្រសិនបើកាលបរិច្ឆេទអាទិភាពត្រូវបានអះអាង និងសេចក្តីអះអាងត្រូវបានទទួលយកកាលបរិច្ឆេទអាទិភាព និងប្រទេសមួយ ឬប្រទេសច្រើនដែលបានទទួលការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំដំបូង និង

ច-ប្រភេទនៃផលិតផលដែលគំនូរឧស្សាហកម្មត្រូវយកទៅប្រើប្រាស់ ។

៤.-ការបោះពុម្ពផ្សាយ នៃសេចក្តីយោងចំពោះការចុះបញ្ជី នៃគំនូរឧស្សាហកម្មអនុលោមតាមមាត្រា ១០៣ នៃច្បាប់ ត្រូវបញ្ជាក់ចំណុចពិសេសៗ ដូចមានចែងក្នុងចំណុច ៣ នៃប្រការនេះ ។

**ប្រការ ១៦.- ការចុះបញ្ជីសារជាថ្មី**

ការចុះបញ្ជីសារជាថ្មី នៃគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោមៈ-

១.-អនុលោមតាមមាត្រា ១០៩ នៃច្បាប់ ការចុះបញ្ជីសាឡើងវិញ អាចត្រូវធ្វើឡើងដោយម្ចាស់ ដែលបានចុះបញ្ជី ឬដោយភ្នាក់ងារតំណាងរបស់គាត់ ក្នុងរយៈពេលប្រាំមួយ(៦)ខែមុនការផុតកំណត់នៃការចុះបញ្ជី ។

២.-ការចុះបញ្ជីសាឡើងវិញត្រូវធ្វើឡើងដោយមានការបង់កម្រៃក្នុងការចុះបញ្ជីសាឡើងវិញ ក្នុងរយៈពេលដែលបានកំណត់ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ឬក្នុងរយៈពេលអនុគ្រោះ ចំនួនប្រាំមួយ (៦) ខែ ដូចមានចែងក្នុងមាត្រា ១០៩ នៃច្បាប់ ដោយមានការបង់

កម្រៃបន្ថែម លើការយឺតយ៉ាវ ។

៣-ការចុះបញ្ជីសាឡើងវិញនៃគំនូរឧស្សាហកម្មត្រូវកត់ត្រានៅក្នុងបញ្ជី និងត្រូវបោះពុម្ពផ្សាយ ។

៤-មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីសាឡើងវិញ ជូនដល់ម្ចាស់ដែលបានចុះបញ្ជីដែលក្នុងនោះ ត្រូវមាន :

ក-លេខចុះបញ្ជីនៃគំនូរឧស្សាហកម្ម

ខ-កាលបរិច្ឆេទនៃការចុះបញ្ជីសាឡើងវិញ និងកាលបរិច្ឆេទនៃការផុតកំណត់

គ-ឈ្មោះ និងអសយដ្ឋានរបស់ម្ចាស់ដែលបានចុះបញ្ជី និង

ឃ-ការបញ្ជាក់អំពីប្រភេទនៃផលិតផល ដែលគំនូរឧស្សាហកម្មត្រូវបានចុះបញ្ជីរួចហើយ ។

**ប្រការ ១៧.- ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាបណ្ណ**

ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាបណ្ណនៃគំនូរឧស្សាហកម្មត្រូវអនុវត្តដូចខាងក្រោមៈ-

១-អនុលោមតាមមាត្រា ១១៤ នៃច្បាប់ សំណើសុំធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិនៃគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីស្របតាមច្បាប់ ឬធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំដែលកំណត់ រួចដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ។

២-ការបោះពុម្ពផ្សាយស្តីពីការប្តូរម្ចាស់កម្មសិទ្ធិត្រូវបញ្ជាក់អំពី :

ក-ចំណងជើងនៃគំនូរឧស្សាហកម្មដែលបានការពារ

ខ-កាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាពប្រសិនបើមាន និងកាលបរិច្ឆេទនៃការចុះបញ្ជី

គ-ម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី និង

ឃ-លក្ខណៈនៃការប្តូរម្ចាស់កម្មសិទ្ធិ ។

៣-កិច្ចសន្យាអាជ្ញាប័ណ្ណដែលបានដាក់ជូនដើម្បីកត់ត្រាយោងតាមមាត្រា ១១៥ នៃច្បាប់ ត្រូវបង់កម្រៃតាមការកំណត់ ។

**ប្រការ ១៨.- ភ្នាក់ងារ**

ភ្នាក់ងារ ត្រូវអនុវត្តដូចខាងក្រោមៈ-

១-អនុលោមតាមមាត្រា ១១៦ នៃច្បាប់ ការចាត់តាំងភ្នាក់ងារតំណាងត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ប្រសិនបើមានអ្នកដាក់ពាក្យសុំលើសពីមួយនាក់ ។ អសយដ្ឋានរបស់ភ្នាក់ងារតំណាង

ត្រូវចាត់ទុកថាជាអសយដ្ឋានទាក់ទងដើម្បីបញ្ជូនដំណឹងទៅបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ ដែលបានចាត់តាំងភ្នាក់ងារនោះ សម្រាប់គោលបំណងទាំងឡាយដែលពាក់ព័ន្ធទៅនឹងច្បាប់ និងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ពន្ធ័ ។

២_លិខិតប្រគល់សិទ្ធិឱ្យភ្នាក់ងារ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះត្រូវភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំ ឬដែលអាចត្រូវប្រគល់ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ ។

៣_ប្រសិនបើការចាត់តាំងភ្នាក់ងារ មិនត្រូវបានអនុវត្តដូចមានចែងក្នុងចំណុច ២ នៃប្រការនេះទេ ហើយមិនស្របតាមមាត្រា ១១៦ នៃច្បាប់ ចំណាត់ការជានីតិវិធីណាមួយ ដែលធ្វើដោយភ្នាក់ងារក្រៅពីការដាក់សំណុំលិខិតស្នើសុំចុះបញ្ជី ត្រូវចាត់ទុកថាមិនបានធ្វើឡើយ ។

៤_ការតម្រូវនានាពាក់ព័ន្ធភ្នាក់ងារតំណាងរបស់អ្នកដាក់ពាក្យសុំ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ត្រូវចែងដោយបទប្បញ្ញត្តិដោយឡែក ដែលកំណត់ដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ១៩._ ថ្ងៃឈប់សម្រាក**

